# ល្បែងប្រជាប្រិយខ្មែរ



រៀបរៀងដោយ :

លោក ចាប-ពិន អធិបតីក្រុមជំនុំ
អ្នកស្រី ពេជ្រ-សល់, លោក លី-ធាមតេង និង ស្តើង-ឆួរ
សមាជិកនៃក្រុមជំនុំ

www.elibraryofcambodia.org

អំណោយពី លោក ទៅ ឃុន សំរឹង ផល់ការណាខ្មែរ
ដើម្បីទុកដាក់ក្នុង eLibrary of Cambodia.
កក្កដា ២015.

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# ល្បែងប្រជាប្រិយខ្មែរ

តាមការស្រាវជ្រាវរបស់ក្រុមជំនុំទំនៀមទម្លាប់

ព្រមទាំងសមាជិកឆ្លើយឆ្លង គ្រប់ខេត្ត

រៀបរៀងដោយៈ

លោក **ចាប ពិន** អធិបតីក្រុមជំនុំ

អ្នកស្រី **ពេជ្រ សល់** លោក **លី ធាមតេង** និង **ស្តើង ធូរ**

សមាជិកនៃក្រុមជំនុំ

គំនូររបស់លោក **ចាប នូ**

ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ

www.elibraryofcambodia.org

# សេចក្ដីកត់ហេតុ

គណៈកម្មការមួយតែងតាំងឡើងដោយ កំណត់ក្រសួងលេខ ៥៥/os ចុះថ្ងៃទី១៣ ខែមិនា គ.ស.១៩៦៤ នៃក្រសួងធម្មការដែលមានសមាសភាពដូចតទៅ:

១- សហជីវិន ចាប ពិន នៅពុទ្ធសាសនបណ្ឌិត្យ ប្រធាន

២- សហជីវិន អ៊ុំម ឆុំ សមាជិករដ្ឋសភា សមាជិក

៣-ឧកញ៉ារាជវរានុកូល តឹម យឹង នៅព្រះបរមរាជវាំង សមាជិក

៤- ឧកញ៉ាប្រសើរលេខា កៅត រឿន សាលាវិចិត្រសិល្បខេមរៈ សមាជិក

៥- សហជីវិន ញូង សឿង នៅពុទ្ធសាសនបណ្ឌិត្យ សមាជិក

៦- សហជីវិន ពេជ្រ សល់ នៅពុទ្ធសាសនបណ្ឌិត្យ សមាជិក

៧-សហជីវិន លី ធាមតេង នៅពុទ្ធសាសនបណ្ឌិត្យ សមាជិក

៨- សហជីវិន ស្ដេង ធូរ នៅពុទ្ធសាសនបណ្ឌិត្យ លេខាធិការ

បានប្រជុំគ្នាអស់១១លើកដើម្បីពិនិត្យសៀវភៅល្បែងប្រជាប្រិយខ្មែរនេះ ដែលក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បានតែងហើយដាក់ស្នើមកអោយគណៈកម្មការនេះពិនិត្យ។

គណៈកម្មការយល់ឃើញថា ទោះបីពុំទាន់បានសព្វគ្រប់ទាំងអស់ដោយសារជាលើកដំបូងក្ដី ក៏សៀវភៅនេះហុចផល

www.elibraryofcambodia.org

អោយល្បែងខ្មែរ ពុំអាចមានអាយុយឺនយូរតទៅបានហើយថែម ទាំងឥទ្ធិពលនៃល្បែង បរទេសចេះតែចូលមកច្រៀតជ្រែកគ្រប សង្កត់ផងទៀត ល្បែងខ្មែរក៏រឹតតែសាបរលាបបន្តិចម្ដងៗ តែការ ចារឹកជាក្បួនតម្រានោះមានការលំបាកក្រៃពេកលុះតែស្រាវជ្រាវរា វរកអស់ពេល យ៉ាងយូរទើបបានសំរេច។

ដើម្បីអោយការកចារឹក នេះឆាប់បានសំរេចលោក **ចាប ពិន** អធិបតីក្រុមជំនុំរួបរួមជាមួយសមាជិកនៃក្រុម ជំនុំទំនៀម ទំលាប់ខ្មែរ ក៏ស្រាវជ្រាវជ្រើសយកល្បែងផ្សេងៗ អំពីឯកសាររបស់ សមាជិកឆ្លើយឆ្លងនៅក្រុងនិងខេត្ត ក្រៅទាំងឡាយដែលមានក្នុង ក្រុមជំនុំទំនៀមទំលាប់ខ្លះ សើបសួរយកការណ៍អំពីលោកអ្នក ចាស់ទុំ ដែលចេះចាំនូវល្បែងនោះ។ ខ្លះរៀបចំចងក្រង ជាសៀវភៅ នេះអោយឈ្មោះថា ល្បែងប្រជាប្រិយខ្មែរ ហើយដាក់អោយគណៈ កម្មាការពិសេសមួយ ដែលតាំងឡើងដោយកំណត់ក្រសួងលេខ ៥៥/០s ចុះថ្ងៃទី១៣ ខែមិនា គ.ស.១៩៦៤ នៃក្រសួងធម្មការពិនិត្យ ថែមរួចចាត់ការបោះពុម្ពឡើង ដើម្បីរក្សាទុកនូវល្បែងជា ប្រពៃណី របស់ជាតិ អោយមានអាយុយឺនយូរ ឋិតថេរចិរកាលជាអង្វែងត ទៅ សំរាប់អោយយុវជនរួមជាតិសម័យ បច្ចុប្បន្ននិងអនាគតជ្រាប ច្បាស់ថាល្បែង ប្រពៃជាតិរបស់ខ្លួនមាន ប្រយោជន៍យ៉ាងណាខ្លះ។

នៅវេលាបោះពុម្ពសៀវភៅនេះលើកទី១ យើងយល់ថាពុំ ទាន់បាន សព្វគ្រប់ល្បែងនៅឡើយទេ។ ដូច្នេះក្រុមជំនុំសូមអំពាវ

www.elibraryofcambodia.org

នាំងដល់លោកអ្នកអានទាំងឡាយបើឃើញថា នៅខ្វះល្បែងអ្វីខ្លះ សូមសរសេរតែងល្បែងនោះដោយសព្វគ្រប់ល្អមធ្វើជាគំរូលេងតាមបានទៅអោយក្រុមជំនុំទំនៀមទំលាប់ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុមជំនុំនេះនឹងរៀបរៀងបញ្ចូល ថែមអោយបានសព្វគ្រប់នៅវេលាបោះពុម្ពលើកទី២តទៅ។

ភ្នំពេញថ្ងៃទី ១៥ មេសា ឆ្នាំ១៩៦៤
ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

www.elibraryofcambodia.org

ព.ស.២៥០៧ គ.ស.១៩៦៤

## អារម្ភបទ

ប្រទេសកម្ពុជាមានល្បែងប្រជាប្រិយច្រើនអនេក ដែលប្រជាពលរដ្ឋទូទាំងប្រទេសនិយមលេងកំសាន្ត នៅពេលទំនេរ ពេលបុណ្យទាន ពេលធ្វើពិធីតូចធំផ្សេងៗ មានពិធីចូលឆ្នាំជាដើម ជាប់ជាប្រពៃណី តាំងពីព្រេងនាយមក។

បើយើងសង្កេតដោយហ្មត់ចត់ សព្វគ្រប់តាមលក្ខណាការរបស់ល្បែងទាំងនោះទៅ នឹងឃើញថាមានប្រយោជន៍ខាងកាយសម្បទាខ្លះ ខាងចិត្តសម្បទាខ្លះ ដែលអាចរាប់ចូលក្នុងពួកអត្តពលកម្មនិងចិត្តពលកម្មបាន គឺជាការហាត់ប្រាណហាត់ភ្នែក ហាត់ជើងដៃអោយរាងកាយកើតសាច់ឈាមមាំមួន មានសុខភាពល្អ មានកំលាំងពលំភ្នែកវៃ ដៃជើងរហ័សរហួន នឹងជាការហាត់ចិត្តគំនិតហាត់ប្រាជ្ញាស្មារតី អោយមានគំនិតវាងវៃ ស្មារតីប៉ិនប្រ៉ៅចេះកលល្បិចផ្សេងៗ មួយទៀតល្បែងទាំងនោះជាអារ្យធម៌ចាស់របស់ខ្មែរ សុទ្ធសាធ ដោយហេតុប្រទេសខ្មែរជាប្រទេសចាស់មួយនៅអាស៊ីភាគអាគ្នេយ៍ មានអាយុរាប់ពាន់ឆ្នាំមកហើយ ម៉្លោះហើយមានបង្កើតជាចំណេះដឹង ភ្លេង ល្បែងជាច្រើន។

ឯល្បែងទាំងនោះ ពុំមានចារឹកជាក្បួនជាតម្រាទេ គេ...
តែតាមចំណាំរបស់គេរៀងៗខ្លួនតៗគ្នា ទៅតាមទម្លាប់ស្រុ...
គេ។ ការដែលពុំបានចារឹកល្បែងរបស់ខ្មែរទុកជាឯ...

www.elibraryofcambodia.org

ប្រយោជន៍ជាច្រើនដល់អ្នកអានទូទៅ ក្នុងការស្គាល់ច្បាស់នៃល្បែងប្រជាប្រិយ ដែលជាអារ្យធម៌ផ្ទាល់របស់ជាតិខ្មែរ។

ក្រោយដែលបានពិនិត្យផ្ទៀងផ្ទាត់សព្វគ្រប់ទៅ គណៈកម្មការបានកែសំរួលខ្លះបន្ថែមសេចក្ដីខ្លះ អោយកាន់តែបានសមរម្យឡើង ល្មមសមគួរអោយយកទៅបោះពុម្ពផ្សាយទុកជាទិដ្ឋានុគតិតទៅ។

ភ្នំពេញថ្ងៃទី៧ វិច្ឆិកា គ.ស.១៩៦៨

ប្រធានគណៈកម្មការ

ហត្ថលេខា: **ចាប ពិន**

សមាជិក

ហត្ថលេខា

-អ៊ុំ ឆុំ

-គីម យឹង

-កៅត វឿន

-ញ៉ូង សឿង

-ពេជ្រ សល់

-លី ធាមតេង

-ស្ដើង ធូរ

www.elibraryofcambodia.org

# បញ្ជីរឿង

អារម្ភបទ..........ទំព័
១-ល្បែង ស្តេចចង់ ឬអៀរ..........០១
២-ល្បែងឈូង..........០៤
៣-ល្បែងចាប់កូនខ្លែង..........០៨
៤-ល្បែងលោតអន្ទាក់..........១៣
៥-ល្បែងលាក់កន្សែង..........១៦
៦-ល្បែងឱបគ្រឡាច..........១៩
៧-ល្បែងប្រជល់មាន់..........២២
៨-ល្បែងគ្របមាន់..........២៤
៩-ល្បែងបិទពួន..........២៧
១០-ល្បែងអង្គុញ..........៣១
១១-ល្បែងគោះពញាក់..........៤១
១២-ល្បែងគោះត្រឡោក..........៤៣
១៣-ល្បែងសី..........៤៦
១៤-ល្បែងទាញព្រ័ត្រ..........៥២
១៥-ល្បែងកូនគោល..........៥៥
១៦-ល្បែងរាំបង្គង..........៥៩
១៧-ល្បែងចោះប្រមាត់..........៦១
១៨-ល្បែងបាយខុំ..........៦៤
១៩-ល្បែងលាក់កូនកាល..........៦៨
២០-ល្បែងលាក់ធ្យូង..........៧០

www.elibraryofcambodia.org

២១-ល្បែងប៉ក់ចាប.............................................................................៧២
២២-ល្បែងចត្រង្គ.............................................................................៧៧

www.elibraryofcambodia.org

www.elibraryofcambodia.org

# ១- ល្បែងស្តេចចង់ ឬ ល្បែងអៀវ

ល្បែងស្តេចចង់ ជាល្បែងមួយ យ៉ាងដែលពួកកុមារាកុមារី ជំទង់ៗគ្រប់ភូមិ - ស្រុក ទូទាំងកម្ពុជរដ្ឋ តែងលេងនៅពេលទំនេរ ក្នុងវេលាយប់ខែភ្លឺ ។ អ្នកលេងមានប្រុសមានស្រីច្រើននាក់ មិនកំណត់ ។ ពេលលេងគេចែកគ្នាជា២ពួក ប្រុស ១ពួក ស្រី ១ពួក ។ ក្នុងបណ្តាអ្នកទាំង ២ ពួកនោះ គេតាំងប្រុស ឬស្រីម្នាក់ឲ្យធ្វើជាស្តេច ឲ្យអង្គុយនៅទីមួយ១៥០ ចំកណ្តាលទី លើកៅអី ឬលើវត្ថុអ្វីមួយ មានត្បាល់ជាដើម ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



កាលអ្នកធ្វើស្តេចអង្គុយលើទីដ៏សមគួរមួយ ហើយ, ខាងស្រីគេឲ្យស្រីម្នាក់ដើរចូលទៅខ្សឹបនឹងស្តេចថា ខ្លួនស្រលាញ់ឈ្មោះណាមួយ


www.elibraryofcambodia.org

ឧបមាថាឈ្មោះ ក ឬ ខ ខ្សឹបហើយគេថយមកអង្គុយ ឬក៏មកឈរនៅកន្លែងដើមវិញ។ ខាងប្រុសគេឲ្យប្រុសម្នាក់ដើរចូលទៅរកស្តេចដែរ ប្រសិនជាមិនចំឈ្មោះដែលគេខ្សឹបទុកជាមុនទេក៏ហីទៅ តែបើប្រុសដែលមកនោះចំលើឈ្មោះ ដែលស្រីគេបានខ្សឹបនោះមែន ស្តេចស្រែកថា "អេរ្យវៗ" ហើយឲ្យស្រីនោះ ជិះប្រុសនោះតម្រង់ទៅរកកន្លែងគេ, កំពុងជិះ គេស្រែកថា "អេរ្យវៗ" ហើយគេបញ្ជិះទៅចុះនៅកន្លែងខាងស្រី ។ រួចហើយខាងប្រុសគេឲ្យប្រុសខាងគេម្នាក់ចូលទៅខ្សឹបម្តង, បើប្រុសនោះចូលទៅខ្សឹបថា " ខ្ញុំស្រឡាញ់នាងណាមួយ ឧបមាថាឈ្មោះ "ខ" ខ្សឹបហើយគេថយទៅវិញ បើស្រីម្នាក់ឈ្មោះ "ខ" ចូលទៅមែន ស្តេចស្រែកថា " អេរ្យវៗ " ហើយឲ្យប្រុសនោះជិះស្រីនោះ ស្រែកថា " អេរ្យវៗ " ដូចគ្នា ។ បានសេចក្តីថាបើខាងណាចូលទៅខ្សឹបថា ខ្លួនស្រឡាញ់ឈ្មោះ "ក" ហើយបែរជាឈ្មោះ "ខ" ចូលមករកស្តេចវិញ នោះស្តេចមិនឲ្យអ្នកខ្សឹបជិះឬអេរ្យវគេទេ អ្នកខ្សឹបនោះត្រូវថយទៅវិញ ហើយគេឲ្យម្ខាងចូលទៅខ្សឹបជាថ្មីទៀត ។ ចេះតែផ្លាស់គ្នាតាមរបៀបនេះរហូតដល់ពេលឈប់ ។

អ្នកដែលធ្វើស្តេចត្រូវមើលការខុសត្រូវក្នុងរឿងនេះ ដោយសច្ចៈ និង យុត្តិធម៌ ។



www.elibraryofcambodia.org

ល្បែងនេះស្រេចលើអ្នកធ្វើស្តេច បើអ្នកធ្វើស្តេចប្រកបដោយអគតិ ចង់ឲ្យអ្នកណាជិះអ្នកណា ក្រៅពីឈ្មោះដែលគេខ្សឹបក៏បាន គឺថាបើម្នាក់ចូលទៅខ្សឹបថាស្រឡាញ់ឈ្មោះ "ក" ហើយទោះបីឈ្មោះ "ខ" ចូលមកស្តេចស្រែកថា " អឿវ " ទៅក៏ចេះតែបាន ព្រោះអ្នកចូលទៅក្រោយ មិនបានឮអ្នកមុនគេខ្សឹបថាស្រឡាញ់ឈ្មោះណាៗ ទេ ។ តែបើមានរបៀបលេងលំអៀងបែបនេះ អ្នកលេងណាដែលចាប់ថ្នាក់បានតវ៉ាឡើង អាចសុំគេឲ្យប្តូរអ្នកធ្វើស្តេចបាន ប្រសិនបើអ្នកធ្វើស្តេចប្រកបដោយសច្ចៈនិងយុត្តិធម៌ នោះការលេងនេះទៀងទាត់ណាស់ ។

ល្បែងនេះជាល្បែងកំសាន្តក៏មែន តែជាល្បែងហាត់ចិត្តមនុស្សឲ្យប្រកបដោយសច្ចៈនិងយុត្តិធម៌ មិនឲ្យប្រកបដោយអគតិ (សេចក្តីលំអៀង) ៤ យ៉ាងគឺ ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់, ទោសាគតិ លំអៀងព្រោះខឹង, ភយាគតិ លំអៀងព្រោះខ្លាច, មោហាគតិ លំអៀងព្រោះភ័ន្តច្រឡំ ។ មួយយ៉ាងទៀត ជាការបង្ហាត់ឲ្យមនុស្សចេះជ្រើសតាំងគ្នា ឲ្យធ្វើការជាតំណាងភ្នែកច្រមុះខ្លួនផងគឺត្រូវចេះជ្រើសរកនរណា ដែលគេយល់ថាជាមនុស្សត្រឹមត្រូវបរិសុទ្ធ ធ្វើការបានល្អតាមគន្លងធម៌ ពិត ៗ ។



www.elibraryofcambodia.org

# ២- ល្បែង ឈូង

ល្បែងឈូង ជាល្បែងមួយយ៉ាង របស់មនុស្សកម្លោះក្រមុំ ឬមនុស្សចំណាស់ៗ ប្រុស - ស្រី ទូទាំងកម្ពុជរដ្ឋ គេតែងលេងនៅវេលាយប់ខែភ្លឺ ក្នុងរដូវចូលឆ្នាំថ្មី ( ខែចេត្រ - ពិសាខ ) ។ គេចែកគ្នាជា ២ ពួក ប្រុស ១ ពួក, ស្រី ១ ពួក ។ ក្នុង ១ ពួក ៗ, មានគ្នាចំនួនពី ១០ នាក់ ឬ ២០ នាក់ ឡើងទៅ ឈរត្រៀមជា ២ ជួរ, ទល់មុខគ្នា ឃ្លាតពីគ្នាប្រមាណជា ៨ ឬ ១០ ម៉ែត្រ ។ គេយកក្រមាឬកន្សែងមកផ្ទួលឲ្យមូលចងរឹតឲ្យតឹងណែនល្អ ទុកឲ្យមានកន្ទុយបន្តិចហៅថា "ឈូង" សម្រាប់កាន់បោះឬចោលទៅមករកគ្នា ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



ឈូងមាន ២ បែប ៖



www.elibraryofcambodia.org

១- ឈូងច្រៀងរាំ

២- ឈូងលោះខ្ញុំ

១- **ឈូងច្រៀងរាំ** មុនដំបូង ពួកខាងប្រុសបោះឈូងទៅឲ្យពួកខាងស្រី, ពួកខាងស្រីប្រុងចាប់កុំឲ្យធ្លាក់ដល់ដី បើធ្លាក់ដល់ដីគេចាត់ជាស្អុយ ហើយគេផ្ដើមបោះទៅឲ្យខាងប្រុសវិញ, ពួកខាងប្រុសប្រុងចាប់កុំឲ្យធ្លាក់ដល់ដី ។ កាលចាប់បានហើយ ចោលសំដៅទៅពួកខាងស្រី គឺសំដៅនាងណាដែលខ្លួនស្ម័គ្រ បើចោលខុសគេចាត់ជាស្អុយ រួចគេផ្ដើមបោះជាថ្មីទៀត បើចោលត្រូវស្រីណាហើយ ស្រីនោះច្រៀងរាំយកឈូងទៅជូនខាងប្រុស ហៅថាច្រៀងរាំជូនឈូង ។ របៀបច្រៀងរាំនោះ ម្នាក់កាន់ឈូងនាំមុខ ម្នាក់ដៃទទេរាំតាមក្រោយ ហើយច្រៀងជាទំនុកថា " **ប្អូនចាប់ឈូងបាន ឈូងបែកជាបួន ព្រលឹងប្រុសស្ងួន ទទួលឈូងទៅ** " ។ ពួកស្រីៗក្រៅពីនោះគ្រប់គ្នាទទួលថា " **ឱណាកែវ កែវពិអា ឱណាកែវអើយ អឺអឺងអឺយ** ! " រួចហើយហុចឈូងនោះទៅឲ្យប្រុស ៗ ទទួលយកហើយក៏ផ្ដើមបោះឈូងនោះទៅឲ្យពួកខាងស្រីចាប់វិញ ។

បើពួកស្រីចាប់ឈូងបាន ក៏ចោលសំដៅទៅពួកប្រុស បើចោលត្រូវប្រុសណា ប្រុសនោះត្រូវរាំនាំឈូងទៅជូនស្រី ដោយ


www.elibraryofcambodia.org

ច្រៀងជាទំនុកថា " **បងចាប់ឈូងបាន បងបីត្រកង ព្រលឹងមាសបង ទទួលឈូងទៅ** " ។ ពួកប្រុស ៗ គ្រប់គ្នាទទួលបន្ទរថា " **ខ្ញុំណាកែវ កែវពីអា ខ្ញុំណាកែវអើយ អឺអឹងអឺយ !** " ហើយក៏ហុចឈូងនោះទៅឲ្យពួកស្រី ៗ ទទួលយក ទើបផ្ដើមបោះតទៅទៀត ។

**២- ឈូងលោះខ្ញុំ** ដើមដំបូង ខាងប្រុសគេផ្ដើមច្រៀង ១ទំនុកជាមុន ។ ឯទំនុកច្រៀងឈូងមានច្រើនបែប ប្លែក ៗ ទៅតាមប្រាជ្ញារបស់អ្នកនាំច្រៀងនិងតាមស្រុក ។ ទីនេះស្រង់យកតែទំនុកធម្មតាដែលអ្នកលេងឈូងគ្រប់ស្រុកគេតែងច្រៀងគ្រប់គ្នាថា ៖ " **បងបោះឈូងទៅ អូនអើយ កំពស់ចុងដូង** (ស្ពូន) **ក្រមុំឈរច្រូង អូនអើយ ទទួលឈូងបង** " ឬថា " **បងបោះឈូងទៅ ឈូងបែកជាបួន ស្រីណាមានខ្លួន ទទួលឈូងបង** " ។ ល ។ ច្រៀងហើយគេស្រែកប្រាប់ថា " ឈូងអើយឈូង! " ហើយអ្នកផ្ដើមទំនុកក៏បោះឈូងទៅលើពួកស្រី ៗ ឲ្យពួកស្រី ៗ ចាប់ ។ ខាងស្រីចាប់ឈូងបាន គេចោលសំដៅទៅរកប្រុសណាដែលត្រូវចិត្ត បើចោលទៅត្រូវប្រុសណា គេទៅចាប់យកប្រុសនោះមកទុកខាងពួក គេ ។ បើចោលមិនត្រូវទេ ខាងប្រុសគេចាប់ឈូងនោះចោល សំដៅមករកស្រីណាដែលគេស្ម័គ្រ បើខាងប្រុសចោលមកត្រូវខាងស្រីហើយ ប្រុសម្នាក់ដែលស្រីចាប់


www.elibraryofcambodia.org

យកទៅលើកមុននោះ ត្រូវបានរួចខ្លួន បើប្រុសចោលមិនត្រូវស្រីវិញទេ ប្រុសម្នាក់នោះត្រូវនៅខាងស្រី ដដែល ។ បើខាងណាប៉ិនប្រសប់គេចោលយកខាងម្ខាងទាល់តែអស់ ។ កាលណាអស់គ្នាហើយគេផ្ដើមលេងសាជាថ្មី ដោយឲ្យខាងស្រីបោះឈូងទៅឲ្យខាងប្រុសមុនវិញ ។ មុននឹងស្រី ៗ បោះឈូងទៅឲ្យប្រុស គេស្រែកច្រៀងថា " **អូនបោះឈូងទៅ បងអើយ កំពស់ចុងស្លា ប្រុសឈរត្រៀបត្រា បងអើយទទួលឈូងប្អូន** " ។ ល ។ ច្រៀងហើយគេស្រែកថា " ឈូងអឺយ ឈូង ! " ហើយគេបោះឈូងទៅលើពួកប្រុស ៗ ។

ឯខាងប្រុស បើគេចាប់ឈូងខាងស្រីបានហើយ គេចោលឈូងនោះសំដៅទៅស្រី ៗ កាលត្រូវលើស្រីណាម្នាក់ គេចាប់យកស្រីនោះមកទុកខាងគេ ។ បើខាងណាអស់មនុស្ស គេចែកគ្នាលេងសាជាថ្មី ។

មនុស្សដែលគេចាប់បាននោះ ជួនកាលគេចងមុខឲ្យជិតលែងឲ្យរត់ទៅកាន់ទីផ្សេង ៗ ជាការកំសាន្តសប្បាយ ។

របៀបលេងបែបទី ២ នេះ ជួនកាលអ្នកលេង គេច្រូតកាត់មិនបាច់ច្រៀង ស្រាប់តែចោលតែម្ដងក៏មាន ។

ល្បែងនេះ រាប់ចូលក្នុងពួកការហាត់ភ្នែកឲ្យវៃ ហាត់ដៃឲ្យត្រង់ផង ជាការកំសាន្តសប្បាយ ដោយមានការរាំច្រៀងលាយជាមួយផង ។


www.elibraryofcambodia.org

# ៣- ល្បែងចាប់កូនខ្លែង

**ល្បែងចាប់កូនខ្លែង** ជាល្បែងរបស់កុមារាកុមារីជំទង់ ៗ តែងលេងក្នុងវេលាយប់ខែភ្លឺ នៅរដូវចូលឆ្នាំ ឬ នៅពេលទំនេរ ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



ល្បែងនេះ ពេលលេងគេចាត់ម្នាក់ដែលមានមាឌមាំធំ ឲ្យធ្វើជាមេហ្វូងហៅថាមេមាន់, ចាត់ច្រើននាក់ឲ្យធ្វើជាកូនមាន់ ហើយគេចាត់ម្នាក់ទៀត ឲ្យធ្វើជាខ្លែង ចាំចាប់កូនមាន់ ។ ម្នាក់ ៗ គេយកក្រមាក្រវាត់ចង្កេះឲ្យតឹងណែន ការពារកុំឲ្យរបូតសំលៀក ។ គេនាំគ្នាបង្កាត់ភ្លើងឲ្យបានជាភ្នក់ ១ តូច ដោយកំទេចឧស ហើយម្នាក់ដែលធ្វើមេមាន់បញ្ជាឲ្យកូនរបស់ខ្លួនតោងចង្កេះត ៗ គ្នា រហូតដល់អស់ ដោយឈរជាជួរ រួចដើរក្រឡឹងព័ទ្ធជុំភ្នក់ ភ្លើង ។ ជាមួយគ្នានេះ មេមាន់ពោលពាក្យចំអកឡកឡឺយឲ្យន័យទៅខ្លែងថា ៖


www.elibraryofcambodia.org

ចាប់កូនខ្លែងប្រឡែងកូនអក

ពពេចញ៉ែកញ៉ក កូនអញតែមួយ ៗ

ជីកអន្លុងដាំត្រកួន

ទន្សាយរត់ពួន ត្រកួនឡើងលាស់ ៗ

ទៀន ១ គូ តាំងយូឬាំងព្រះ

លើកដៃសំពះ ជូន ៗ សុំភ្លើង ៗ

*ចំណែកម្នាក់ដែលធ្វើខ្លែងឈរធ្វើព្រងើយ, កាលបានឮមាន់និងកូនមាន់ស្រែកដូច្នោះ ក៏ដើរចូលទៅរកភ្នក់ភ្លើង ហើយនិយាយសុំភ្លើងថា* "ជូន ៗ សុំភ្លើង !" ។

*មាន់ឆ្លើយថា* : រលត់

*ខ្លែងសុំថា* : សុំមួយអង្គត់

*ម*[១] រលាយ

*ខ-* សុំទឹកឬាយ

*ម-* ឆ្អែលិទ្ធ

---

[១] ម. មេមាន់ ៗ ខ⁻ ខ្លែង ៗ



www.elibraryofcambodia.org

ខ- សុំកាំបិត

ម- មិនទាន់ប្រុង

ខ- សុំល្ពុង

ម- មិនទាន់ដាំ

ខ- សុំថ្នាំ

ម- មិនទាន់ហាល

ខ- សុំផាល

ម- មិនទាន់សិត

*ហើយខ្លែងក៏អង្គុយនៅបៀតភ្នក់ភ្លើងនោះ ។*

*ចំណែកមេមាន់ក៏នាំកូនរបស់ខ្លួន ដើរប្រទក្សិណព័ទ្ធជុំវិញខ្លែង និង ភ្នក់ភ្លើង[១] ហើយស្រែកច្រៀងទាំងមេទាំងកូនថា ៖*

**ចាប់កូនខ្លែងប្រឡែងកូនមាន់** (*បន្ទរ*) **អាឡូយ ៗ**

**បើមេទៅទាន់ យកមាន់ទៅលោក** (*បន្ទរ*) **អាឡូយ ៗ**

---

[១]- ស្រុកខ្លះគេអង្គុយទល់មុខគ្នា ឆ្លើយឆ្លងទៅមក លុះដល់ពាក្យសុំកូនមាន់ ហើយមេមាន់អនុញ្ញាតថា កំបាក់កំបែកយកមួយចុះ ត្រង់នេះគេក្រោកឈរស្រែឡើង ៗ



www.elibraryofcambodia.org

ឈាក់ទុកឯណា ឈាក់ក្បាលដំណោក (បន្ទរ)អាឡេយៗ

រលើកពីដេក វាយមាន់តួងតាង ៗ

មាន់ច្រៀងចប់ក៏ឈប់ឈរតម្រៀបគ្នា ។

ខ្លែងក៏ស្រែកសុំភ្លើងម្តងទៀតថា "ដូនៗសុំភ្លើង"ៗ

មាន់ឆ្លើយថា " ក្អែកពាំទៅទម្លាក់ក្នុងទឹកទន្លេបាត់ទៅហើយ "

រួចក៏ដើរព័ទ្ធជុំវិញខ្លែងនិងភ្នក់ភ្លើង ហើយច្រៀងតទៅទៀតថា ៖

ប្អូនវេញខ្សែសូត្រ បង្ហូតខ្សែគោម (បន្ទរ) អាឡេយ ៗ

ខ្លែងអើយកុំលោម មិនបានមាន់ទេ (បន្ទរ) អាឡេយៗ ហើយ

ឈរស្ងៀម ។

ខ្លែងក៏និយាយទទូចសុំកូនថា :

ខ- ដូន ៗ ឲ្យសុំកូនមុខ

ម- ឪពុកមិនឲ្យ

ខ- សុំកូនក្រោយ

ម- កំប្លាក់កំបែកយកចុះ

ខ្លែង កាលបានឮមេមាន់ថា ឲ្យកូនណាកំប្លាក់កំបែកដូច្នេះ ក៏តាំងដេញចាប់បេះយកកូនណាដែលនៅក្រោយគេ, ឯមេមាន់ខំ



www.elibraryofcambodia.org

ប្រឹងការពារកូនរបស់ខ្លួនកុំឲ្យគេបេះយកបាន, ឯកូនមាន់ក៏ខំប្រឹងតោងចង្កេះគ្នាយ៉ាងជាប់ រត់ពេនចុះពេនឡើង ខ្លាចខ្លែងចាប់បេះយកខ្លួនម្នាក់ ៗ បាន ។ ជួនក៏ខ្លែងបេះយកកូនបានម្ដង ១ ម្ដង ២ ទាល់តែអស់ ជួនក៏បេះបានតែ ១ ។ តែគេមានលក្ខខ័ណ្ឌមួយថា បើកូនណារបូតចេញពីមេព្រោះប្រឹងគេចខ្លាំងហើយកូននោះគេក្រាបទៅនឹងដី នោះមេខ្លែងមិនត្រូវចាប់គេទេ ។ កាលអស់កម្លាំងហត់រៀងខ្លួនហើយ ក៏ឈប់សម្រាកបន្តិចហើយផ្លាស់ប្ដូរគ្នាលេងតទៅទៀត គេលេងតែរបៀបនេះរហូតដល់ពេលឈប់ ។

ប៉ុន្តែល្បែងបែបដូចគ្នានេះ នៅស្រុកខ្លះ គេហៅតម្រូវន័យតាមរបៀបលេងថា " ល្បែងខ្លែងចាប់កូន មាន់ " ក៏មាន ។

ល្បែងនេះ ជាការបង្ហាត់មនុស្សឲ្យចេះប្រុងស្មារតី ប្រុងស្មារតីឲ្យរហ័សរហួន ចេះការពារខ្លួននិងគ្រួសារ ផង។


www.elibraryofcambodia.org

# ៤- ល្បែងលោតអន្ទាក់

**ល្បែងលោតអន្ទាក់** ជាល្បែងសម្រាប់កុមារាកុមារីជំទង់ ៗ លេងក្នុងវេលាយប់ នៅរដូវចូលឆ្នាំ ឬ នៅពេលទំនេរខ្លះ តាមដែលគេស្ម័គ្រ ។ បានជាគេហៅថា "ល្បែងលោតអន្ទាក់" ព្រោះល្បែងនេះមានមនុស្សមួយពួកអង្គុយច្រហោងដំកង់ ចាប់ចុងដៃគ្នាជាអន្ទាក់ដៃ ចាំស្ទាក់អ្នកលោតកុំឲ្យលោតចូលបាន, មួយពួកទៀតឈរជុំវិញចាំលោតរំលងឲ្យចូលទៅក្នុងអន្ទាក់ដៃនោះ ។ របៀបលេងល្បែងនេះ គេចែកពួកអ្នកលេងជា២ ចំនួន ស្មើគ្នា គឺចាប់តាំងពី ៥ ឬ ៦ នាក់ម្ខាងឡើងទៅ ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ៖



ពួកទី ១ អង្គុយច្រហោងដំកង់គ្នាជារង់ ឃ្លាតពីគ្នាល្មមលាតឬកាងដៃទាំងពីរខាងបាន ហើយចាប់ចុងដៃគ្នានិងគ្នា មើលទៅឃើញភាពដូចជាអន្ទាក់ ។

ពួកទី ២ ឈរជុំវិញ ចាំលបឆ្មក់ លោតចូលក្នុងអន្ទាក់ដៃ



www.elibraryofcambodia.org

របស់ពួកទី ១ ។

ពេលលេង ពួកទាំង ២ នេះ សុទ្ធតែប្រឹងប្រយ័ត្នរៀងខ្លួន គឺមុននឹងលោតចូល ពួកអ្នកឈរគេធ្វើរ៉ែរ៉ ៗ ជុំវិញពួកអ្នកអង្គុយ ឲ្យពួកអ្នកអង្គុយភ្លេចខ្លួន ឬពួកអ្នកលោតគេចាត់ឲ្យពួកគេខ្លះទៅពួននៅទីឆ្ងាយ ហើយឲ្យលួចរត់ពីចម្ងាយមកលោតចូលតែម្ដងក៏មាន ។ ចំណែកខាងពួកអ្នកអង្គុយធ្វើអន្ទាក់ក៏ប្រុងប្រយ័ត្នដែរ ដើម្បីកុំឲ្យពួកអ្នកលោត លោតផ្លោះចូលមកក្នុងរង្វង់បាន ។ ឯពួកអ្នកអង្គុយគេលើកដៃឡើង ដោយប្រញ៉ាប់ជាបន្ទាន់ ដើម្បីកុំឲ្យគេលោតចូលបាន ឬដើម្បីលើកដៃគះឲ្យប៉ះជើងអ្នកលោត ។ បើអ្នកអង្គុយគះប៉ះជើងអ្នកលោតបានហើយ គេទុកអ្នកលោតជាចាញ់ អ្នកធ្វើអន្ទាក់ជាឈ្នះ ហើយអ្នកឈ្នះក្រោកឈរឡើងចាំលោត ឲ្យអ្នកចាញ់ទៅអង្គុយធ្វើអន្ទាក់វិញ ។ ឯពួកអ្នកលោតនោះ បើមានអ្នកណាម្នាក់លោតចូលបានដោយស្រួលគេឲ្យគ្នាគេទាំងអស់ចូលតាមទៅក្នុងវង់អន្ទាក់នោះ ហើយពួកអ្នកលោតចូលបាននោះ គេនាំគ្នាលោតចេញវិញ គឺអ្នកលោតចូលបាននោះ គេឈរគ្រប់គ្នាគាបជើងលើអន្ទាក់ដៃអ្នកអង្គុយគ្រប់គ្នា ទុកជើងម្ខាងនៅក្នុង ជើងម្ខាងនៅក្រៅអន្ទាក់ដៃនោះ ។ បើក្នុងបណ្ដាពួកអ្នកលោតនោះ មានអ្នកណាម្នាក់ លោតចេញដោយស្រួលបាន មិនប៉ះដៃអ្នកអង្គុយ គេនាំគ្នាចេញតាមទាំងអស់ ។ តែការចេញនិងចូលបាន



www.elibraryofcambodia.org

នោះត្រូវចេញ ឬចូលឲ្យចំច្រកដែលលោតរំលងបាននោះ បើខុសច្រកនោះទេទុកជាចាញ់ ។ ហើយការលោតចូល ឬលោតចេញនោះ ត្រូវតែលោតម្តងម្នាក់ បើជួនជាស្របពីរនាក់ស្មើគ្នា ក៏គេទុកជាចាញ់ដែរ ។ គេចេះតែផ្លាស់ប្តូរគ្នាលេងតាមរបៀបនេះរៀងទៅដរាបដល់ពេល ឈប់ ។

ល្បែងនេះ ជាល្បែងកំសាន្តមួយយ៉ាង ដែលចាត់ចូលក្នុងកីឡាហាត់ប្រាណ គឺហាត់កាយឲ្យមានសុខភាព មានកម្លាំងកាយរឹងប៉ឹង ហាត់ភ្នែកឲ្យវៃ ហាត់ស្មារតីឲ្យចេះប្រុងប្រយ័ត្នចេះប្រើគំនិតឲ្យវាងវៃកុំឲ្យអ្នកដទៃបំភ័ន្តបាន ។



www.elibraryofcambodia.org

# ៥- ល្បែងលាក់កន្សែង

**ល្បែងលាក់កន្សែង** ជាល្បែងមួយយ៉ាងរបស់ក្មេងខ្មែរក្នុងបុរាណកាល តែងលេងសម្រាប់ជាទីកំសាន្តសប្បាយ នៅពេលយប់ខែភ្លឺក្នុងរដូវចូលឆ្នាំ ឬនៅពេលជាចន្លោះការហាត់នឿយម្តង ៗ ។

មុនដំបូង ពួកក្មេងៗគេបបួលគ្នាបានចំនួនពី ៦-៧នាក់ឡើងទៅឲ្យអង្គុយច្រហោងដំកង់ជារង់មូល ដាក់ដៃទាំងពីរទៅមុខលើក្បាលជង្គង់ក្នុងទីណាមួយ ដែលជាទីវាលស្រឡះរាបស្មើល្អ ។ ហើយគេយកកន្សែងឬក្រមាតូចមួយមករុំមូរផ្នួលរឹតឲ្យតឹងណែនល្អ ទុកជាយបន្តិចសម្រាប់កាន់យួរបាន សន្មតហៅថា កន្សែង មានម្នាក់ក្រោកចេញទៅក្រៅរង់កាន់កន្សែងនោះ ដើរព័ទ្ធជុំវិញយ៉ាងលឿន ពីខាងក្រោយខ្នងអ្នកអង្គុយបញ្ឆោតអ្នកអង្គុយមិនឲ្យដឹងខ្លួនថា គេលាក់កន្សែងក្រោយខ្នងអ្នកណា ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពខាងមុខ នេះ ៖



ល្បែងនេះ មានត្រណមយ៉ាងតឹងរ៉ឹងមិនឲ្យអ្នកលេងងាកក្រោយ ឬលូកដៃទៅខាងក្រោយខ្នង បើអ្នកណាមួយហ៊ានងាក ឬ



www.elibraryofcambodia.org

លូកស្ទាបខាងក្រោយខ្នង អ្នកលាក់គេមានអំណាចដាក់ទណ្ឌកម្ម អ្នកនោះ មិនឲ្យឡើងលាក់កន្សែង ឬគេឲ្យអ្នកនោះអង្គុយធ្មេចភ្នែកក៏បាន ស្រេចតែគេដាក់ទោសយ៉ាងណាតាមចិត្តគេ ស្ម័គ្រ ។ អ្នកលាក់ លុះរត់ក្រឡឹងអ្នកអង្គុយ ២-៣ជុំហើយ មើលតែអ្នកណាអង្គុយបែបភ្លេចខ្លួនគេក៏ដាក់កន្សែងក្រោយខ្នងអ្នកនោះភ្លាម រួចគេរត់យ៉ាងរហ័សព័ទ្ធវង់អ្នកអង្គុយ ដើម្បីឲ្យឆាប់មកដល់កន្លែងកន្សែងដែលគេដាក់នោះ ។ បើអ្នកដែលត្រូវគេលាក់កន្សែងពីក្រោយខ្នងនោះមិនដឹងខ្លួន លុះអ្នកលាក់គេរត់ក្រឡឹងមកម្តងទៀតចាប់យកកន្សែងនោះបានមុន គេទុកអ្នកលាក់នោះជាឈ្នះ ត្រូវមានអំណាចរើសយកកន្សែងទៅគក់ខ្នង អ្នកដែលអង្គុយនោះហើយគេយកកន្សែងលាក់តទៅទៀត ។ តែបើអ្នកអង្គុយដឹងខ្លួនថា គេលាក់កន្សែងចំក្រោយខ្នងខ្លួន ហើយចាប់យកកន្សែងបានមុនអ្នកលាក់រត់មកដល់ គេទុកអ្នកអង្គុយនោះជាឈ្នះ ត្រូវមានអំណាចក្រោកឡើងចាប់កន្សែង ដេញគក់អ្នកលាក់នោះវិញ តែបើអ្នកនោះគេរត់ទៅដល់កន្លែងចន្លោះអង្គុយបានទៅ អ្នកកាន់កន្សែងនោះ មិនត្រូវគក់គេទេ ត្រូវរត់ក្រឡឹងអ្នកអង្គុយដំកង់ ដើម្បីនឹងលាក់តទៅទៀត គឺថា អ្នកលាក់ពីមុនត្រូវទៅអង្គុយកន្លែងអ្នកចាប់កន្សែងបានក្នុងវង់ដដែល ។

គេលេងតែរបៀបនេះរហូតដល់ពេលឈប់ ។ ជួនកាលអ្នក


www.elibraryofcambodia.org

ខ្លះមិនដែលបានឡើងលាក់កន្សែងនឹងគេម្តងសោះក៏មានព្រោះគេលាក់កន្សែងក្រោយខ្នងខ្លួន ខ្លួនមិនដឹង រវល់តែគេគក់ខ្នងបានរាល់ពេល ។

ល្បែងនេះ គេលេងដើម្បីហាត់ខ្លួន ឲ្យមានស្មារតីរឹងប៉ឹងរហ័សរហួន ឲ្យមានប្រាជ្ញាវាងវៃ ហាត់ទម្លាប់ខ្លួនឲ្យចេះប្រុងស្មារតីជានិច្ច ។


www.elibraryofcambodia.org

# ៦- ល្បែងឱបត្រឡាច ឬ បេះឪឡឹក

**ល្បែងខ្មែរ មានច្រើនបែប** ល្បែងខ្លះគេលេងតែក្នុងពេលថ្ងៃ ល្បែងខ្លះគេលេងតែក្នុងពេលយប់ខែភ្លឺ ល្បែងខ្លះគេលេងតែក្នុងពេលបុណ្យមានបុណ្យចូលឆ្នាំជាដើម ល្បែងខ្លះគេលេងមិនកំណត់ពេល ។

ល្បែងដែលលេងតែក្នុងពេលយប់ខែភ្លឺ ហើយមិនចាំបាច់មានបុណ្យទានអ្វីនោះ មាន **ល្បែងឱប ត្រឡាច ឬ បេះឪឡឹក** ជាដើម ។ ល្បែងនេះ ជាល្បែងកំសាន្តសប្បាយ របស់ពួកកុមារាកុមារី នៅគ្រប់និគមជនបទនៃប្រទេសកម្ពុជា ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



របៀបលេង មុនដំបូង ពួកកុមារប្រុសស្រី ស្រុះស្រួលចិត្ត


www.elibraryofcambodia.org

បបួលគ្នាឲ្យមានចំនួនច្រើន រួចហើយគេចាត់ម្នាក់ឲ្យធ្វើម្ចាស់ត្រ-ឡាច ឬឪឡឹកម្នាក់ទៀតឲ្យធ្វើអ្នកទិញសល់ប៉ុន្មានគេឲ្យធ្វើត្រឡាច ឬឪឡឹកទាំងអស់ហើយអ្នកលេងទាំងនោះ គេសំដៅទៅរកគល់ឈើ ឬជង្គត់អ្វីមួយ ឲ្យតែមានទំហំល្មមឱបបាន, ដោយហោចទៅសសរផ្ទះក៏បានដែរ ឲ្យតែជាទីវាលស្រឡះល្អ។ កាលបានកន្លែងស្រួលបួលហើយ, ក្មេងម្នាក់ជាទី ១ ក្នុងបណ្ដាក្មេងដែលគេឲ្យធ្វើត្រឡាច ឬឪឡឹកនោះ អង្គុយឱបដើមឈើ ឬសសរនោះទាំងជើងទាំងដៃ, ក្មេងម្នាក់ទៀតជាទីក្មេង ២ អង្គុយឱបចង្កេះ យកជើងទាំងពីរដាក់លើភ្លៅក្មេងទី ១, ក្មេងទី ៣ យកដៃនឹងជើងឱបក្មេងទី ២ ដូចក្មេងទី ២ ឱបក្មេងទី ១ ដែរ ឯក្មេងដទៃទៀតក៏បន្តគ្នារហូតទាល់តែអស់ពួកក្មេងដែលត្រូវធ្វើត្រឡាចឬឪឡឹក។ ឯក្មេងម្នាក់ដែលគេឲ្យធ្វើជាម្ចាស់ត្រឡាចឬឪឡឹកឈរធ្វើព្រងើយ ដើររេរា ៗ ក្បែរក្មេងជាត្រឡាចឬឪឡឹកទាំងនោះ ហើយក្មេងម្នាក់ទៀត ដែលគេឲ្យធ្វើជាអ្នកទិញមកសួរតម្លៃអ្នកលក់បីដូចជាគេទិញធម្មតា ។ តម្លៃគ្នាត្រូវរ៉ូវហើយក៏ឲ្យអ្នកទិញបេះតាមចិត្ត ។ អ្នកទិញក៏ដើរយកដៃគោះខ្នងក្មេងដែលអង្គុយឱបគ្នានោះ ។ គោះបណ្ដើរសួរបណ្ដើរថា ខ្ចីឬទុំ ? ។ អ្នកបន្ត ៗ ពីដើមទៅ ចេះតែឆ្លើយថាខ្ចី ៗ លុះដល់អ្នកចុងក្លែបំផុតទើបឆ្លើយថាទុំ រួចអ្នកទិញក៏បេះយកអ្នកដែលនៅចុងគេបំផុតនោះទៅ ដោយខំប្រឹងទាញមែនទែន ព្រោះ


www.elibraryofcambodia.org

អ្នកអង្គុយឱបគ្នាគេខំរឹបឱបចំកោងខ្នងតៃរៀងខ្លួន តាំងពីអ្នកខាងចុងរហូតអ្នកខាងគល់ រេចុះរេឡើង ដោយអ្នកបេះប្រឹងទាញខ្លាំងពេក ។ អ្នកបេះក៏បេះប្រលេះបានមួយម្តងដរាបដល់អស់មនុស្ស ជួនកាលក៏បេះបាន ២-៣-៤ នាក់ តាមដែលអ្នកខាងដើមឱបជាប់ ឬមិនជាប់ បេះបានប៉ុន្មានយកមកដាក់ ១ ដុំ, បើអ្នកទិញបេះមិនបាន ដោយកម្លាំងខ្សោយជាងគេនោះ ក៏រើលេងសាជាថ្មីម្តងទៀត ។ ឯអ្នកលក់អ្នកទិញត្រឡាចទៅធ្វើជាអ្នកឱប ហើយអ្នកឱបមុនក៏ប្តូរទៅធ្វើជាអ្នកលក់អ្នកទិញវិញ ។ គេធ្វើដោយរបៀបនេះរហូតដល់ពេលឈប់លេង ។

ល្បែងនេះ ជាកីឡារបស់ខ្មែរសម័យបុរាណ សម្រាប់ហាត់ដៃ ហាត់ជើងឲ្យមានកម្លាំងពលំមាំមួន ឲ្យមានសាច់ដុំល្អ មានសុខភាពស្រួលបួល ។


www.elibraryofcambodia.org

## ៧- ល្បែងប្រជល់មាន់

**ល្បែងប្រជល់មាន់** ជាល្បែងមួយយ៉ាងរបស់ពួកកុមារាកុមារី ជំទង់ ៗ ទូទៅក្នុងកម្ពុជរដ្ឋ គេតែងលេងកំសាន្តក្នុងវេលាយប់ ។ សមាសភាពនៃអ្នកលេងល្បែងនេះ មានគ្នា ៤ នាក់ គឺប្រុសម្នាក់ធ្វើមាន់ឈ្មោលស្រីម្នាក់ធ្វើមាន់ញី ប្រុសម្នាក់ស្រីម្នាក់ធ្វើជាអ្នកចាំឲ្យទឹកមាន់ ។ ពេលលេងប្រុសម្នាក់ស្រីម្នាក់ដែលធ្វើមាន់ចូលទៅឱនក្រាបទន្ទឹមគ្នា មួយបែរមុខទៅខាងជើង មួយបែរមុខទៅខាងត្បូង ។ ឯប្រុសម្នាក់ដែលធ្វើជាអ្នកចាំឲ្យទឹកចូលទៅឈរក្បែរមាន់ឈ្មោលមាន់ញីរបស់ ខ្លួនចាំឲ្យទឹកមាន់ខ្លួន ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



ពេលរៀបឲ្យមាន់ជល់គ្នា ម្ចាស់មាន់គេទះដៃស្រែកឡើងថា "យើងបានគ្នាហើយ" ។ បន្ទាប់ពីម្ចាស់មាន់ស្រែក តួមាន់ក៏រៀប



www.elibraryofcambodia.org

ខ្លួនចូលទៅជល់ ដោយកាងដៃឡើងធ្វើបែបមាន់ទទះស្លាប ហើយដើរឱន ៗ ចូលទៅឈរជិតគ្នា មានអាការដូចរអួតជល់គ្នា តែមិនឲ្យប៉ះទង្គិចស្មាឬប៉ះដៃគ្នាទេ គ្រាន់តែលើកដាក់ដៃទាំង ២ តាមចង្វាក់ពាក្យច្រៀងរបស់ម្ចាស់មាន់ប៉ុណ្ណោះ ។ ពេលនោះ ម្ចាស់មាន់គេច្រៀងឡើងថា "មាន់នាងនីវ៉ៃយ ៗ ជល់នឹងមាន់នាងនល់ លោកឲ្យប្រជល់ វ៉ឺយ ៗ មាន់យើងឈ្នះគេ" ។ កាលម្ចាស់មាន់ច្រៀងហើយមាន់ទាំងពីរក៏លោតចូលទៅឈរកណ្ដាលរង្វង់ ហើយលោតចេញមកវិញ ចេញមកហើយចូលទៅវិញទៀត ដោយធ្វើអាការទទះស្លាបដូចមុន ម្ចាស់មាន់ក៏ស្រែកច្រៀងដូចមុនម្ដងទៀត ។

មាន់ខាងណាមានអាការក្លៀវក្លា ស្វាហាប់ក្លាហានខ្លាំងពូកែជាងគេ ក្នុងវេលាជល់ គេទុកជាឈ្នះ ។ កាលបើមាន់ ១ គូមុនដឹងឈ្នះចាញ់ហើយ ម្ចាស់មាន់គេឲ្យមាន់ផឹកទឹក គឺឲ្យផឹកទឹកត្នោត ឬឲ្យស៊ីបបរជាដើម ជាកំសាន្តសប្បាយ ហើយគេរៀបចំប្រ-ជល់សាជាថ្មី តទៅទៀត ។ គេលេងតែរបៀបនេះ រហូតដល់ពេលឈប់ ។

ល្បែងនេះ អាចរាប់ចូលក្នុងកីឡាសម្រាប់បង្ហាត់ក្មេងឲ្យមានទំលាប់ប្រកាន់នូវសេចក្ដីក្លាហានបាន ។


www.elibraryofcambodia.org

# ៨- ល្បែងគ្របមាន់[១]

**ល្បែងគ្របមាន់** ជាល្បែងកំសាន្តមួយយ៉ាងរបស់ពួកកុមារា កុមារីជំទង់ ៗ គ្រប់ភូមិ-ស្រុក ទូទៅទាំងប្រទេសកម្ពុជា ដែលតែងតែលេងនៅពេលទំនេរ ក្នុងវេលាយប់ខែភ្លឺ ។ អ្នកលេងមានស្រីមានប្រុសមានគ្នាតាំងពី ៥ នាក់ ឬ ១០នាក់ម្ខាងឡើងទៅ ។ របៀបលេងគេជ្រើសយកក្មេងប្រុសម្នាក់ស្រីម្នាក់ ក្នុងបណ្ដាពួកគេទាំង ២ នោះ មកគ្របសំពត់ឬក្រមា ឲ្យជិតខ្លួនតាំងពីក្បាលដល់ចុងជើង ដើម្បីកុំឲ្យស្គាល់ជានរណា ហើយគេឲ្យក្មេងពីរនាក់នោះ ក្រាបបែរមុខរកគ្នា គឺខាងប្រុសតំណាងមាន់ឈ្មោល ខាងស្រីតំណាងមាន់ញី ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



១- ស្រុកខ្លះ គេហៅថា ល្បែងលាក់មាន់ ។



www.elibraryofcambodia.org

កាលក្រាបហើយគេឲ្យពួកខាងប្រុសម្នាក់ គោះខ្នងមាន់ខាងស្រីឲ្យរងាវ មាន់ខាងស្រីរងាវថា " កិកកិកែកីត " ឡើង ដោយខំធ្វើសម្លេងឲ្យប្លែកពីធម្មតា ។ តែបើស្ដាប់សួរមិនបានគេអាចគោះឲ្យរងាវបានបីដង ពួកខាងប្រុសចាំស្ដាប់សម្លេងមាន់ខាងស្រីនោះ ហើយគេទាយតាមឈ្មោះមនុស្សស្រីដែលគេស្គាល់, ទាយហើយគេបើកគម្របឡើង បើត្រូវ គេយកមាន់នោះមកទុកជារបស់គេ រួចហើយខាងស្រីគោះមាន់ខាងប្រុសឲ្យរងាវម្ដង ។ មាន់ខាងប្រុសរងាវថា "កិកកិកែកីត" ដូចគ្នា ។ ពួកខាងស្រីចាំស្ដាប់សម្លេងមាន់ខាងប្រុសនោះ ហើយគេទាយតាមឈ្មោះមនុស្សប្រុសដែលគេស្គាល់ បើខាងស្រីទាយត្រូវ ខាងប្រុសគេយកមាន់ខាងស្រីដែលគេយកទៅនោះមកសងស្រីវិញ តែបើខាងស្រីទាយខុស ខាងប្រុសគេយកមាន់ខាងស្រីនោះទៅទៀត ។

ការទាយសម្លេងមាន់ ស្រេចលើខាងណាទាយត្រូវច្រើន គេបានមាន់ច្រើន, ខាងណាទាយខុសច្រើន ត្រូវបង់ខាតមាន់ច្រើនដែរ ។ គេធ្វើរបៀបនេះទាល់តែម្ខាងៗ អស់មាន់ទាំងអស់ ឬអស់មាន់ច្រើនជាងគេទុកជាចាញ់ ខាងណាបានមាន់ច្រើន គេទុកជាឈ្នះ ហើយគេរៀបចំជាថ្មីឡើងវិញ ។ គេចេះតែធ្វើរបៀបនេះ ដ-រាបដល់ពេលណាដែលគេសន្មតគ្នាថាឈប់ ទើបលែងលេង ។

ល្បែងនេះ ជាល្បែងកំសាន្តមួយយ៉ាង សម្រាប់កុមារាកុមារី


www.elibraryofcambodia.org

ជំទង់ ៗ លេងតាមសប្បាយ ដែលជាល្បែងហាត់បញ្ញា ហាត់គំនិតឲ្យប៉ិនប្រសប់ខាងស្តាប់  ខាងកាត់ប្រមាណតម្រូវតាមសម្លេងរបស់មនុស្ស ។


www.elibraryofcambodia.org

# ៩- ល្បែងបិទពួន

**ល្បែងបិទពួន** ជាល្បែងមួយ យ៉ាងដែលពួកកុមារាកុមារី ជំទង់ ៗ តែងលេងកំសាន្តសប្បាយនៅពេលរាត្រីខែភ្លឺ ។ ល្បែងនេះ គេលេងគ្មានកំណត់ខែណា រដូវណាទេ នៅខែណា រដូវណាក៏បាន ឲ្យតែមានពេលលំហែ ហើយគ្មានកំណត់ចំនួនមនុស្សទៀយ ។ វិធានការនៃល្បែងនេះ គឺពួកម្ខាងអ្នកពួន ពួកម្ខាងទៀតអ្នកដើររក, កាលរកឃើញគេដេញចាប់ពួកអ្នកពួន ដើម្បីញៀច (មួលស្លឹកត្រចៀក) ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



របៀបលេង, មុនដំបូង គេបបួលកុមារាកុមារីដែលមានអាយុស្របាល ៗ គ្នា ឲ្យបានច្រើនប្រមាណ ៥ ឬ ១០ នាក់ឡើងទៅ ស្រេចតែមានគ្នាតិចឬច្រើន ចែកជាពីរផ្នែកស្មើគ្នា ស្រីម្ខាងប្រុសម្ខាង ឬលាយចម្រុះគ្នាទាំងស្រីទាំងប្រុស ឬក៏សុទ្ធតែប្រុស សុទ្ធតែ



www.elibraryofcambodia.org

ស្រីក៏បាន ។ គេកំណត់កន្លែងណាមួយ ដែលមានភាពដីស្រឡះ ឲ្យឈ្មោះថា "ទី" ហើយគេឲ្យពួកម្ខាងទៅពួននៅទីដទៃ គឺត្រូវពួនរបៀបណាកុំឲ្យពួកម្ខាងទៀតរកឃើញបានដោយងាយ ពួកម្ខាងទៀតឈរធ្មេចភ្នែកឬបិទភ្នែកនៅក្នុងទី ។ ត្រណាមរបស់ពួកនេះនៅត្រង់ធ្មេចភ្នែក គឺគេសន្យាគ្នាថា អ្នកណាលួចមើលពួកគេអ្នកពួន ឲ្យដឹងថាគេពួនត្រង់នេះត្រង់នោះ នឹងត្រូវស្ទួយភ្នែក ។ ចំនួន ២-៣ នាទី ទើបពួកអ្នកនៅក្នុងទីបើកភ្នែកឡើងស្រែកថា "បើកគ្របបាយ កំចាយរក អ្នកណាមិនមក អញរកឃើញ" ហើយក៏ចាត់ម្នាក់ រើសរកអ្នកណាមានមាឌមាំបន្តិច ក្នុងបណ្តាពួកអ្នកនៅចាំទីនោះ ឲ្យនៅចាំទីការពារ កុំឲ្យពួកអ្នកទៅពួនរត់មកចូលទីបាន សល់ប៉ុន្មានឲ្យដើររកគ្រប់ទីកន្លែងដែលកំបាំងៗ ។ បើអ្នកណាមួយឃើញអ្នកពួនណាម្នាក់ ក៏នាំគ្នាដេញចាប់ញៀចបើដេញញៀចបានឈ្មោះថាស្អុយ បើមិនបាន អ្នកពួននោះរត់ចូលទីបាន ឈ្មោះថាបានរួចខ្លួន មិនត្រូវដេញញៀចគេទៀតទេ, ប៉ុន្តែអ្នកពួននោះ បើចូលទីហើយត្រូវស្រែកឲ្យខ្លាំង ៗ ថា "ចូលទី" បើមិនស្រែកទេគេមានអំណាចញៀចបានទៀត ។ លុះអ្នកដើររករកឃើញពួកអ្នកពួនអស់ហើយ ឬបើមិនទាន់ឃើញអស់គេខំដើររកឲ្យទាល់តែឃើញ ទោះបីញៀចបានក៏ដោយមិនបានក៏ដោយមកជួបជុំហើយ គេក៏និយាយប្រាប់អ្នកទាំងអស់គ្នា (ទាំងពីរផ្នែក)


www.elibraryofcambodia.org

ថា ពួកគេញៀចបានប៉ុណ្ណោះនាក់ ប៉ុណ្ណោះនាក់តាមដែលគេញៀចបាន រួចហើយពួកអ្នកនៅចាំទីមុននោះទៅពួនវិញ, ឯពួកអ្នកពួនមុនត្រូវនៅក្នុងទី ហើយដើររកគេ ផ្លាស់ប្តូរគ្នាតែរបៀបនេះរហូតដល់ពេលឈប់លេង ។

ក្នុងការផ្លាស់ប្តូរគ្នានេះ គឺទៅពួនម្តងមួយផ្នែក រួចហើយបើពួកខាងម្ខាងញៀចគេបាន ៣-៤ នាក់ ដល់ពួកម្ខាងទៀតញៀចគេវិញបានតែ ២-៣ នាក់ ពួកនោះ ឈ្មោះថាចាញ់គេ ។

តាមរបៀបអ្នកស្រុកខ្លះ គេលេងប្លែកពីនេះបន្តិច គឺគេប្រមូលអ្នកស្ម័គ្រលេងទាំងប៉ុន្មានមកឈរដំកង់ ហើយម្នាក់ផ្តើមសូត្រថា " ត្រៃត្រក ត្រៃត្រេង " ឬថា "កាច់ស្លឹកឫស្សី សំដីល្ង ខែចែត្រពេញបូណ៌លោកឲ្យលេងពួន លេងខែណាលេងខែដូងព្រះកាច់សន្ទះមហាទង់ដែង អញ្ចៀងអញ្ចាក់ អញ្ចៀងចង្វាក់ អអ៊ុតអន្ទង អំពងអំពួន ប្រពន្ធចៅហ្វាយ " ។ ក្នុងការសូត្រពាក្យទាំងនេះគេចង្អុលបណ្តើរទៅចំខ្លួនមនុស្សម្នាក់ ៗ គឺមួយម៉ាត់ចង្អុលម្នាក់ ៗ បើអស់ចំទៅលើរូបអ្នកណា អ្នកនោះត្រូវរត់ទៅរកកន្លែងពួន រួចធ្វើដូចមុនទៀតរហូតដល់សល់តែម្នាក់ក្រោយគេ ទុកជាអ្នកនៅចាំទី ។ កាលណាអ្នកទៅពួនស្រែកថា " រួច " អ្នកចាំទីដើរតាមរកញៀច, បើញៀចបាននរណាមួយ ត្រូវប្តូរអ្នកនោះមកចាំទីម្តង ឯអ្នកចាំទីមុនត្រឡប់ទៅពួនវិញ ។ តែញៀចម្តងបានតែមួយនាក់


www.elibraryofcambodia.org

ទេ ទោះជាគេពួននៅជិតគ្នាក៏ដោយ ហើយបើខុសពីត្រណមនេះ គេទុកជាស្អុយ គេរៀបចំលេងសាជាថ្មីម្តងទៀត ធ្វើតែយ៉ាងនេះបន្ត ៗ ទៅ។ ប្រសិនជាយូរពេលហើយនរណាមួយគេខ្ជិលពួន អាចរត់គេចពីភ្នែកអ្នកចាំទីមកអង្គុយត្រង់ទីក៏បាន ចាំគេញៀចបាននរណាថ្មីទៀត សឹមរត់ទៅពួនម្តងទៀត ។ កាលណាអ្នកណាម្នាក់ចង់ឈប់លេងត្រូវស្រែកឲ្យរហ័សថា "បើកបាយក្រហាយទឹក អ្នកណាមិនមកឈប់លេង " បើគេស្រែកដូច្នេះរួច អ្នកចាំទីគ្មានទិញៀចគេទៀតទេ។

ល្បែងនេះ ជាល្បែងអាចចាត់ចូលក្នុងពួកកីឡាហាត់ប្រាណបាន ត្រង់ការរត់ ការស្ទុះ ការលោត ការ ដេញ ។



www.elibraryofcambodia.org

# ១០- ល្បែងអង្គញ់

**ល្បែងអង្គញ់** គេឲ្យឈ្មោះតាមវត្ថុដែលគេយកមកលេង គឺផ្លែអង្គញ់ ដែលក្រៀមស្ងួត ។ ល្បែងនេះគេលេងបានទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង នៅវេលាថ្ងៃ ឬវេលាយប់ខែភ្លឺ នារដូវចូលឆ្នាំ ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



ល្បែងអង្គញ់ គេលេងបានតាំងពីគ្នាពីរនាក់ឡើងទៅដល់ដប់[១]នាក់ដោយចែកចេញជាពីរពួកមានចំនួនស្មើគ្នា ដែលមានស្រីម្ខាងប្រុសម្ខាងក៏បាន ចំរុះគ្នាទាំងសងខាងក៏បាន ។ អង្គញ់ដែលគេយកមកលេងនេះឲ្យឈ្មោះថា "កោយ" ចែកចេញជាពីរផ្នែកដែរ គេហៅថា កោយដាំមួយពួក កោយបោះមួយពួក ។ កោយមួយ ពួក ៗ មានចំនួន ៣ ឬ ចំនួន ៥ គឺថាបើដាំកោយ ៣

[១]- បើគ្នាតិច គេនិយមប្រើកោយតែ ៦ ទេ គឺដាំ ៣ បោះ ៣ តែបើគ្នាច្រើន គេដាំ ៥ បោះ ៥ ប៉ុន្តែគេមិនឲ្យតិចឬច្រើនលើសពីនេះទៀតទេ ។



www.elibraryofcambodia.org

ក៏បោះកោយ ៣, បើដាំកោយ ៥ ក៏បោះកោយ ៥ តាមចំនួនអ្នកលេងមានគ្នាតិចឬច្រើន ។ ដែលហៅថាកោយដាំ គឺគេដាំភ្ជាប់នៅនឹងដីមានជួរបែកកន្លែកចេញពីកោយកណ្ដាលមួយដែលហៅថា "មេក្លោង ឬ កន្លោង" មួយឬពីរខាងស្ដាំ មួយឬពីរខាងឆ្វេងមានសណ្ឋានដូចក្អែកទឹកហើរ ដែលឲ្យមេខ្យល់មួយនាំមុខហើយក្អែកទាំងហ្វូងបែកគ្នាជាពីរជួរបញ្ឆៀង ៗ គ្នាពីក្រោយ ។ រីឯកោយបោះគឺកោយទាំងឡាយដែលគេកាន់យកទៅទីហើយបោះក្ដី ធ្វើអ្វីគ្រប់បែបទៀតក្ដីសំរាប់រំលំកោយដាំទាំងប៉ុន្មាននោះ ។ ត្រង់រណ្ដៅតូច ៗ ដែលឆ្មៀលដីយកកន្លែងដាំកោយឲ្យជាប់នោះ គេហៅថា "រន្ធ ឬ រន្ធកោយ" ។ គេកំណត់កន្លែងមួយពីមុខកោយដាំប្រមាណជា ៣ ឬ ៤ ម៉ែត្រ សន្មតហៅថា " ទី " គឺជាទីដែលគេត្រូវទៅបោះ ឬទៅធ្វើបែបអ្វីមួយពីត្រឹមនោះតម្រង់មកកោយដាំវិញ ។ អ្នកដែលត្រូវឡើងមុន គឺបានទៅបោះពីទីមុនគេ នោះសម្រេចលើការព្រមព្រៀងគ្នា, ជាធម្មតា គេច្រើនតែអនុញ្ញាតឲ្យពួកអ្នកខ្សោយជាងមានសិទ្ធិទៅបោះមុនគេ ទុកដូចជាតទីឲ្យដែរ ។ ឯការចាញ់ឈ្នះស៊ីសងត្រង់នរណាធ្វើត្រូវកោយដាំចប់សព្វគ្រប់មុនគេ គឺគ្រប់បែបគ្រប់ថ្នាក់ដែលរបៀបលេងអង្គុញតម្រូវឲ្យទាំងប៉ុន្មាន ។ ប៉ុន្តែគេច្រើនសន្មតគ្នាបន្ថែមឲ្យអ្នកចាញ់ធ្វើ ៣ ឬ ៤ក្ដារសិន ហៅថា " តាម " ដូច្នេះ បានជាមុននឹងលេង គេសន្មតគ្នាថា តាមប៉ុន្មាន



www.elibraryofcambodia.org

ក្តារ ? បើគេសម្រេចគ្នាថាប៉ុន្មាន ៗ ដល់ទីបំផុតត្រូវតែ " តាម " ប៉ុណ្ណោះក្តារសិន ។ បើផុតកំណត់ហើយនៅតែមិនបានធ្វើត្រូវអស់ទៀតនោះ ទើបទុកជាចាញ់ ហើយពួកខាងឈ្នះត្រូវដោះពួកខាងចាញ់ តាមចំនួនដែលគេសន្យាគ្នា ឧបមាថា គេសន្យាថាកោយមួយដោះ ១០ ដូច្នេះនរណាកាន់កោយបោះមួយ បើឈ្នះត្រូវបានដោះគេ ១០ តែបើចាញ់ក៏ត្រូវឲ្យគេដោះ ១០ ដែរ ។

ល្បែងនេះ មានល័ក្ខខ័ណ្ឌតឹងរ៉ឹងណាស់ បើធ្វើខុសបទវិន័យណាមួយ នឹងត្រូវទទួលពិន័យភ្លាមមួយរំពេច ។ ល័ក្ខខ័ណ្ឌទាំងនេះ យើងនឹងបរិយាយក្នុងរបៀបលេងខាងក្រោមនេះ ។

ល្បែងអង្គញ់ ចែកចេញច្រើនជាន់ថ្នាក់ជា សង្កាត់ ៗ មាន ៖

**១- បោះ** (កាន់បោះមកពីទីតម្រង់កោយដាំ)

**២- ស៊ីគោល** (បាញ់ដោយម្រាមដៃដាក់លើក្បាលជង្គង់)

**៣-ស៊ីប៉ាផត**(បាញ់ដោយម្រាមដៃដាក់ផ្ទាល់នឹងដី)

**៤- ត្រកង** (ប្រមៀលអង្គញ់មកពីទី)

**៥- ចាក់ខ្នែក**(ដាក់អង្គញ់លើខ្នងជើងដើរបីជំហាន)

**៦- បោះដោះ** (បោះសម្រេចជាចុងក្រោយបំផុត)

របៀបលេង ក្នុងសង្កាត់និមួយ ៗ មានដូចតទៅ ៖


www.elibraryofcambodia.org

**ថ្នាក់ទី ១ បោះ**= ពួកអ្នកដែលត្រូវឡើងទៅបោះ គេបោះតម្រង់ទៅកោយដែលដាំណាមួយ, កាលបោះទៅត្រូវកោយដាំនោះហើយ កោយនោះក៏ខ្ទាតចេញពីរន្ធទៅ កោយបោះក៏នៅក្នុងរន្ធកោយដាំ, ហើយអ្នកដាំទះកោយបោះនោះបង្កប់ថែមទៀតយ៉ាងនេះគេហៅថា " ស្អុយ " ។ បើបោះត្រូវកោយណាមួយហើយដល់បោះកោយ ១ ក្រោយទៅត្រូវកោយដដែលទៀតគេហៅថា " ម៉ាយ " ។ បើអ្នកបោះប្រព្រឹត្តខុសវិន័យទាំងនេះហើយ ត្រូវអ្នកដាំទៅបោះ អ្នកបោះមកដាំវិញម្តង ។ កាលណាបោះទៅត្រូវកោយដែលដាំដួលទាំងអស់រួចហើយ អ្នកបោះត្រូវចាប់បន្តធ្វើស៊ីគោលតទៅទៀត ។

**ថ្នាក់ទី ២ ស៊ីគោល**= កាលបើបោះត្រូវអស់ហើយគេយកកោយរបស់គេដើរសំដៅទៅ "ទី" ហើយអង្គុយច្រហោងរុញក្បាលជង្គង់ម្ខាងទៅមុខបន្តិច យកកោយដាក់លើក្បាលជង្គង់នោះ ផ្ទាត់កោយដោយមេដៃឬចង្អុលដៃតម្រង់ទៅកោយដាំណាមួយ ។ បើកោយផ្ទាត់ទៅនោះធ្លាក់ជិតកោយដាំពេកប្រមាណជា ១ ចំអាម ឬកន្លះចំអាមនោះ, អ្នកស៊ីគោលគេសួរអ្នកដាំថា **"វ័ធ ឬ ណាប់ ?"** បើអ្នកដាំឆ្លើយថា " វ័ធ " អ្នកស៊ីគោលត្រូវវាស់ជាចំអាម ដោយយកមេដៃដាក់លើកោយរបស់ខ្លួនចង្អុលដៃវ័ធកោយដាំឲ្យដួលតែ


www.elibraryofcambodia.org

ម្តង ។ បើអ្នកដាំឆ្លើយថា " ណាប់ " អ្នកស៊ីគោលគេលើកកោយរបស់គេគប់ទៅកោយដាំនោះឲ្យដួលតែម្តង ។ ដូចនេះ កោយដែលស៊ីគោលធ្លាក់ជិតពេកនោះ គេឲ្យឈ្មោះថា **"រ៉ៃ ណាប់"** ។ បើកោយដែលស៊ីគោលទៅហើយធ្លាក់ឆ្ងាយពីកោយដាំ ជាង ១ ចំអាមនោះ អ្នកស៊ីគោលគេត្រូវលុតជង្គង់ ហើយយកកោយនោះមកដាក់លើក្បាលជង្គង់ផ្ទាត់តម្រង់ ទៅកោយដាំបន្តទៅម្តងទៀតទាល់តែអស់កោយរបស់ខ្លួន ។ បើកោយស៊ីគោលនោះរត់ទៅប៉ះគ្នា ដូចជាកោយស៊ីគោលទៅមុនធ្លាក់ត្រង់កន្លែងណាមួយហើយកោយទៅក្រោយរត់ទៅប៉ះកោយមុននោះ ដល់ពេលអ្នកបាញ់គេទៅបាញ់ម្តងទៀតនោះ អ្នកដាំគេត្រូវពិន័យដូច្នេះ គឺកោយមុនគេឲ្យផ្ទាត់ដោយស្រលៀងភ្នែកម្ខាង គឺឲ្យធ្មេចភ្នែកម្ខាង ឯកោយក្រោយគេឲ្យផ្ទាត់ដោយខ្វាក់ភ្នែក គឺឲ្យធ្មេចភ្នែកទាំងសងខាង ។ ដូច្នេះ ទើបគេឲ្យឈ្មោះកោយ ២ នេះថា កោយខ្វាក់និងស្រលៀងតាមទណ្ឌកម្មដែលគេពិន័យ ។ បើស៊ីគោលដូចបានរៀបរាប់មកនេះ ត្រូវកោយដាំដួលអស់ហើយ គេត្រូវធ្វើស៊ីប៉ារេតតទៅទៀត ។

**ថ្នាក់ទី ៣ ស៊ីប៉ារេត**=ពួកអ្នកស៊ីគោលនោះ កាលបានធ្វើស៊ីគោលរួចហើយ គេនាំគ្នាយកកោយទៅដាក់ផ្ទាល់នឹងដី ហើយបាញ់ដោយម្រាមដៃមួយម្តង ៗ តម្រង់ទៅរកកោយដាំ រហូតដល់អស់កោយ ។ ការពិន័យមាន រ៉ៃ ណាប់ ស្រលៀង ខ្វាក់ របៀប


www.elibraryofcambodia.org

ដូចស៊ីគោលដែរខុសគ្នាតែត្រង់ស៊ីគោលគេធ្វើលើក្បាលជង្គង់, ចំ-ណែកស៊ីប៉ារេតដាក់កោយផ្ទាល់នឹងដីតែប៉ុណ្ណោះ ។ លុះធ្វើស៊ីប៉ា-រ៉េតរួចហើយ គេធ្វើត្រកងតទៅទៀត ។

**ថ្នាក់ទី ៤ ត្រកង ឬ ត្រឡងកង=** ក្រោយដែលធ្វើស៊ីប៉ារេតត្រូវអស់ហើយ គេចាប់ធ្វើបន្តទៅទៀតគឺត្រកង ។ ត្រកងនេះ គឺគេប្រមៀលកោយ (គ្រាប់អង្គញ់) ឲ្យរមៀលដូចបរកង់ ហេតុនេះបានជាគេហៅថា "ត្រកង ឬ ត្រឡងកង" ។ ត្រកងមានពីរបែប, គេយកបែបណាមួយមកលេងក៏បានតាមតែគេណាត់គ្នា ហៅថាត្រកងទប់និងត្រកងឆា ។ ត្រកងទប់, គឺគេប្រមៀលកោយទៅហើយត្រូវរត់តាមទៅយកដៃខ្ទប់ឲ្យទាន់មុនកោយនោះដួល ហើយមិនឲ្យហួសមេក្លោងផង តែបើទប់មិនទាន់បណ្តោយឲ្យកោយដួលស្ងៀមខ្លួនវា ឬទប់ដែរតែមិនបានយកដៃខ្ទប់ឲ្យជិតល្អលើកោយនេះទេនោះគេទុកជាស្អុយមិនបានការ, ពួកខាងម្ខាងត្រូវឡើងធ្វើម្តង ។ បើកោយនោះរត់លឿនពេកទៅហួសមេក្លោង ឬមួយក៏ទង្គិចដួលកោយដាំណាមួយក៏ទុកជាស្អុយ ត្រូវគេ "ឡើង" ដែរ ។ ឯត្រកងឆាវិញពុំពិបាករត់តាមខ្ទប់ទេ តែត្រូវមានវិន័យមិនឲ្យហួសមេក្លោងនិង ទង្គិចកោយដាំឡើយ ។ របៀបត្រកង ក៏ដូចជាស៊ីគោល ឬស៊ីប៉ារេតដែរគឺធ្វើបានពីរដំណាក់ គឺត្រកងពីទីទៅដល់ត្រង់ណាហើយ អាចតាមទៅបាញ់ដោយម្រាមដៃផ្ទាល់នឹងដីតម្រង់ទៅ


www.elibraryofcambodia.org

កោយដាំម្ដងទៀត ។ ប្រសិនជាមានរះដួលកោយដាំម្ដង ២ ឬ ៣; ម៉ាយ; ងីងើមិនដួលកោយដាំនោះ; គ្រាន់តែរង្គើក៏ត្រូវទទួលបទពិន័យដូចមុន ៗ ដែរ។

**ថ្នាក់ទី ៥ ចាក់ខ្នែក**= ចាក់ខ្នែកមានរបៀបប្លែកពីមុន ៗ គឺគេឈានមួយជំហានពីគំនូសទី[១] រួចយកអង្គញ់ដាក់លើខ្នងជើង ហើយឈានពីរជំហានទៅមុខទៀត ទើបរលាស់ចុងជើងគ្រវាត់គ្រាប់អង្គញ់ទៅឲ្យត្រូវកោយដាំ ។ កាលណាមិនត្រូវក៏ស្អុយកោយបោះនោះចោលទៅ កាលណាត្រូវ អាចយកកោយដដែលនោះមកធ្វើសាជាថ្មីបានម្ដងទៀត ។ ប្រសិនជាដាក់កោយលើខ្នងជើង ហើយឈានពុំទាន់ដល់កោយដាំ ស្រាប់តែជ្រុះកោយទៅ នោះគេទុកជាបាក់កល្បៀនអណ្ដាត គឺគេឲ្យយកទៅធ្វើម្ដងទៀតតែឲ្យអ្នកនោះងើយកឡើងលើល្បៀនអណ្ដាត មិនឲ្យមើលទៅកោយដាំទេ គឺថាធ្វើប្រថុយ ៗ តាមស្មាន ។ ចាក់ខ្នែកឥតធ្វើពីរដំណាក់គឺតាមទៅផ្ចាត់បាញ់នៅជិតកោយដាំដូចត្រកង ស៊ីគោល-ស៊ីប៉ារ៉េតទេ គេធ្វើយកត្រូវពីទីតែម្ដង ។ កាលបើមានរះ, ម៉ាយ, កប់ គេពិន័យដូចធ្វើអ្វី ៗ ពីមុនមកដែរ ។

**ថ្នាក់ទី ៦ ប្ដោះជោះ**= ប្ដោះជោះក៏ដូចជាបោះពីដំបូងដែរវិន័-

---

[១] ដួនកាលគេមិនឈានសោះ ដាក់កោយពីទីមកតែម្ដងក៏មាន រាលណាគេជាជើងឆើតដូច គ្នា ៗ



www.elibraryofcambodia.org

យគ្រប់បែបគ្រប់យ៉ាងដូចគ្នាទាំងអស់សុទ្ធសាធ ។ គិតទៅបោះដោះនេះ ហាក់ដូចជាគ្រាន់តែជាវិញ្ញាសាមួយសម្រាប់រង់ចាំ ពួកខាងឃើតជាង ឲ្យបានឱកាសដេញតាមតែប៉ុណ្ណោះ ។ បានជាហៅថា បោះដោះព្រោះបន្ទាប់តែពីបោះនេះទៅ ត្រូវបានដោះហើយ (គ្រាន់តែរង់ចាំឲ្យគេតាមប៉ុន្មានក្តារ ដែលបានសន្មតមកតែប៉ុណ្ណោះ) ។

របៀបដោះ គឺគេយកអង្គញ់មួយផ្ទាប់ទៅដល់ក្បាលជង្គង់ ហើយយកអង្គញ់មួយទៀតវាយដោះពីលើរាប់ចំនួនតាមដែលគេត្រូវដោះ ។ ធ្វើបែបនេះហៅថា "ដោះបាយត្រជាក់" ។ មួយបែបទៀតហៅថា "ដោះបាយក្តៅ" របៀបនេះគេផ្ទួបអង្គញ់ពីរតម្រួតគ្នា គឺមួយផ្តេកមួយបញ្ឈរ ហើយដោះខ្លាំង ៗ ទៅលើក្បាលជង្គង់មួយ ៗ ឡើងក្រហមសាច់ ទំរាំតែអស់ចំនួន ៣០-៤០ សឹងតែហើមក្បាលជង្គង់តែម្តង ។ ជួនកាលគេយកបំពង់ឬស្សីមកខោកក្បាលជង្គង់ ធ្វើជាដោះជំនួសគ្រាប់អង្គញ់ក៏មាន ។

ឯឈ្មោះពិន័យដែលប្រើក្នុងល្បែងអង្គញ់នេះ មាន ៩ បែប ៖

១- **ស្អុយ** ( គឺធ្វើខុស ទុកក្រោយនេះជាអសារបង់ )

២- **ម៉ាយ** ( ត្រូវម្តងហើយ ត្រូវដដែលម្តងទៀត )

៣- **រ៉ះ** ( កោយបោះមួយ ត្រូវកោយដាំម្តងពីរ )



www.elibraryofcambodia.org

៤- **ងើងើ** ( កោយបោះរត់ប៉ះកោយដាំឲ្យរង្គើ មិនដួល )

៥- **ស្រលៀង-ខ្វាក់** ( ព្រោះកោយបោះទង្គិចគ្នា )

៦- **វ៉ៃ ណាប់** ( កោយបោះជិតកោយដាំពេក )

៧- **ធ្លាក់កលៀនអណ្ដាត** ( ចាក់ខ្នៃកធ្លាក់កោយកណ្ដាលទី )

៨- **កប់ទះ** ( កោយដាំខ្ទាតចេញ កោយបោះនៅក្នុងរន្ធដាំ )

៩- **ហួសមេដំបូល** ( សម្រាប់ត្រកង កុំឲ្យហួសមេភ្លោង )

បទពិន័យលើកំហុសទាំងអស់នេះ មិនជាការធ្ងន់ពីបាក ប៉ុន្មានទេ មានកំហុសខ្លះគេគ្រាន់តែ " ឡើង " គឺគេទុកក្ដារនេះជាអសារបង់ ត្រូវផ្ទេរឲ្យពួកម្ខាងទៀតឡើងទៅធ្វើម្ដង ដូចយ៉ាងម៉ាយរះ កប់ទះ ជាដើម ប៉ុន្តែទោះជាត្រូវ " ឡើង " ក្ដី ក៏លើកក្រោយគេអនុញ្ញាតឲ្យពួកនេះទុកជាធ្វើត្រូវទាំងអស់នោះដែរ ។ ឯបទពិន័យផ្សេងទៀតក៏គ្រាន់តែដាក់ទណ្ឌកម្មឲ្យ លំបាកក្នុងការធ្វើតែប៉ុណ្ណោះ ពុំទាន់ចាត់ទុកឲ្យកោយនោះស្អុយភ្លាម ៗ ទេ ។ ដូច្នេះ បទពិន័យគ្រាន់តែឲ្យបានសប្បាយ បានយូរបន្តិចប៉ុណ្ណោះឯង ។

**សេចក្ដីបញ្ជាក់ :**

គ្រាប់អង្គញ់ដូចគ្នានេះ គេអាចយកទៅលេងជាល្បែងមួយទៀត ហៅថា " លេងគេល " ។ គឺថា គេយកកោយដាំប្រាំដែរ ដាំ



www.elibraryofcambodia.org

ដង្កៃជាមួយជួរ ហើយមានគូសទីមួយជាកន្លែងសន្មត ដាក់កោយបោះប្រាំដែរ តែដាក់ផ្ទាល់នឹងដី ។ គេយកជើងកៀស គឺជើងឆ្វេងឈរសៀមលូកទៅមុខ, ជើងស្តាំថយមកក្រោយ ចុចកែងឲ្យជាប់ទៅនឹងដី ហើយចុងម្រាមឆ្កើសយ៉ាងខ្លាំង ឲ្យកោយរត់ទៅត្រូវកោយដាំម្តងមួយ ៗ ទាល់តែអស់ បើកោយណាមិនបានត្រូវកោយដាំទេ គេទុកជាស្អុយ តែបើបានត្រូវគេឲ្យត្រឡប់យកមកកេល ( ឆ្កើសចុងម្រាមជើង ) បានម្តងទៀត ។ ពួកខាងណាធ្វើត្រូវអស់មុនឈ្មោះថាឈ្នះ អាចដោះអ្នកចាញ់បាន ។

របៀបលេងគ្រាប់អង្គញ់មួយយ៉ាងទៀត គេហៅថា "បាញ់រង" គឺមានអ្នកលេងពីរពួក ។ ពួកម្ខាង ៗ មានកោយដប់រៀងខ្លួនគឺសម្រាប់ដាំប្រាំ សម្រាប់បាញ់ប្រាំ ។ គេដាំជួរតម្រៀបគ្នាម្ខាងម្នាក់ហើយយកកោយបាញ់ បាញ់ទៅខាងពួកបរបក្ខម្តងម្នាក់ ខាងណាបាញ់រំលំរបស់ពួកខាងគេអស់មុន ឈ្មោះថាឈ្នះ បានដោះគេ ឯបាញ់នេះ គឺឈរបត់ក្បាលជង្គង់ម្ខាង ដាក់កោយលើក្បាលជង្គង់បាញ់នឹងម្រាមដៃតម្រង់ទៅកោយដាំតែម្តង។

ល្បែងអង្គញ់ អាចរាប់ចូលក្នុងពួកកីឡាហាត់ដៃឲ្យត្រង់ហាត់ភ្នែកឲ្យវៃ ហាត់ស្មារតីឲ្យមូលបាន ។


www.elibraryofcambodia.org

# ១១- ល្បែងគោះពញ្ញាក់ ឬ ទះពញ្ញាក់

**ល្បែងគោះពញ្ញក់ និង ទះពញ្ញក់** ជាល្បែងមួយយ៉ាងរបស់មនុស្សជំទង់ ៗ ឬចំណាស់ៗ ដែលត្រូវការលេងក្នុងវេលាថ្ងៃ នៅពេលមានបុណ្យទាន ពេលមង្គលការ ពេលចូលឆ្នាំថ្មី ឬក៏ពេលទំនេរ ។

ល្បែងនេះលេងបានទាំងប្រុសទាំងស្រី ។

គោះពញ្ញក់មានអ្នកលេងតែម្នាក់, ឯទះពញ្ញក់មានពីរនាក់ ។

**របៀបគោះពញ្ញក់**= មុនដំបូងបង្អស់ អ្នកលេងគេអង្គុយពែនភ្នែន លើកដៃប្រណម្យសំពះគ្រូ ឬ សំពះព្រះ ហើយលាដៃទាំងសងខាង ហាមាត់ចំហ ដៃឆ្វេងទះថ្ពាល់ស្ដាំ ដៃស្ដាំទះថ្ពាល់ឆ្វេង ញាក់ចិញ្ចើម ក្អក់ ៣ដង ងាកចុះងាកឡើង ហើយចេះតែក្អក់ឲ្យឮប៉ែស ៗ ត ៗ ទៅ តាមចង្វាក់គោះ ៥ ថ្នាក់ គឺ **ទី ១ គោះដៃ, ទី ២ គោះថ្ពាល់, ទី ៣ គោះក្រោមចង្កា, ទី ៤ គោះពោះ, ទី ៥ គោះត្លៅទាំងសងខាង ៗ**

លុះគោះគ្រប់ទាំង ៥ ថ្នាក់ហើយ គេចាប់គោះពី ទី ១ មកវិញ សាចុះសាឡើងរឿយ ៗ ដើម្បីឲ្យពួកអ្នកទស្សនា កើតសេចក្ដី


www.elibraryofcambodia.org

រីករាយ សប្បាយជាកំសាន្ត ។

**របៀបទះពញ្ញាក់**= មានសកម្មភាព ដូចរូបភាព នេះ ៖



ល្បែងនេះ ដំបូងបង្អស់ អ្នកលេងគេអង្គុយពែនភ្នែនទល់មុខគ្នាពីរនាក់ ដៃទាំងបួនផ្គុំគ្នា រួចហូតចេញពីគ្នាមកវិញ[១] ទើបទះដៃខ្លួនឯងមួយផ្ទូងម្នាក់, ទះភ្លៅខ្លួនឯង ទាំងសងខាង, វិលមកទះដៃរៀងខ្លួនមួយផ្ទូងម្នាក់ទៀត ហើយទះដៃឆ្វេងផ្ទប់គ្នាពីម្នាក់ទៅម្នាក់ រួចទះដៃខ្លួនឯងមួយផ្ទូងទៀតទើបលូកដៃស្តាំទៅទះផ្ទប់គ្នា ទៀត។ គេធ្វើតែរបៀបនេះឲ្យរឹតតែញាប់ឡើង ៗ នរណាកាន់ដៃទះមិនទាន់ គេទុកជាចាញ់ ។ បែបនេះគេ ហៅថា "ពញ្ញាក់ញី" រីឯពញ្ញាក់ល្មាល គេសង្ខេបជាងនេះ គឺទះភ្លៅតែម្តងដំបូងប៉ុណ្ណោះ លុះលំដាប់ត ៗ ទៅ គ្មានទះភ្លៅទៀតទេ ។

ល្បែងនេះ រាប់ចូលក្នុងវិធីហាត់ប្រាណបាន ដែល នាំឲ្យដៃមានសាច់ដុំ ឲ្យដៃរហ័សរហួន នឹងឲ្យភ្នែកវៃចេះសង្កេតហេតុការណ៍ផ្សេងៗ។

---

[១]- របៀបផ្គុំដៃគ្នានេះ គេធ្វើតែម្តងដំបូង, ឯលំដាប់តទៅ មិនច្បាច់,ទ ៗ



www.elibraryofcambodia.org

# ១២- ល្បែងគោះត្រឡោក

**ល្បែងគោះត្រឡោក** ជាល្បែងមួយយ៉ាងរបស់មនុស្សប្រុស ជំទង់ ៗ កម្លោះ ៗ ឬប្រុសចំណាស់ ៗ ដែលគេលេងក្នុងពេលណាក៏បាន តែគេច្រើនតែត្រូវការលេងក្នុងពេលលើកជំនូន-ស៊ីស្លា ឬមង្គលការកូន គឺពេលហែកូនប្រុសទៅជូនជំនូន ឬ ទៅចូលរោងនៅផ្ទះខាងស្រី, ក្នុងពេលនោះ គេតែងរកអ្នកចេះគោះត្រឡោកមកលេងជាកំសាន្ត ។

មនុស្សអ្នកលេងមានតែម្នាក់ទេ ។ មុននឹងលេង គេយកត្រឡោកល្អ ៗ ២ ទំហំប៉ុនគ្នា មកកាន់នៅដៃ ស្តាំ ១ ឆ្វេង ១ ហើយគេអង្គុយ ឬឈរ គោះប្រជល់គ្នាតាមចង្វាក់ មាន ៧ គឺ៖

**ទី ១ គោះលើក្បាល**

**ទី ២ គោះខាងមុខ**

**ទី ៣ គោះខាងក្រោមឃ្លៀកស្តាំ**

**ទី ៤ គោះខាងក្រោមឃ្លៀកឆ្វេង**

**ទី ៥ គោះខាងក្រោមជើងស្តាំ**


www.elibraryofcambodia.org

ទី ៦ គោះខាងក្រោមជើងឆ្វេង

ទី ៧ គោះខាងក្រោយខ្នង

សកម្មភាពរបស់អ្នកគោះបែបអង្គុយ ដូចក្នុងរូបភាពនេះ ៖



លុះគោះគ្រប់ ៧ ថ្នាក់ហើយ គេចាប់គោះពីទី ១ សាជាថ្មីឡើងទៀត តាមលំដាប់ហូរហែទៅ ។

បើគោះបែបឈរ គេគោះបណ្ដើរ ដើរបណ្ដើរ ច្រៀងបណ្ដើរតាមបទ ឬទំនុកដែលគេចេះ ។ នៅពេលហែកូនកម្លោះទៅជូនជំនូន ឬទៅចូលរោងការ ឬនាំកូនក្រមុំចុះពីផ្ទះទៅចូលរោងខាងប្រុស គេតែងគោះបែបឈរ, គឺអ្នកគោះត្រឡោក គេឈរអរាំធ្វើជាស្កាក់មុខកូនកម្លោះមិនឲ្យឡើងទៅលើផ្ទះខាងស្រី ឬ កូនក្រមុំមិនឲ្យចូលទៅរោងខាងប្រុស ។ បើម្ដាយឪពុកនៃសាមុីខ្លួនទាំងសងខាងអាណិតគ្នា កុំឲ្យឈរយូរពេក ខ្លាចនឿយហត់ ឬ ខ្មាសគេ គេ

www.elibraryofcambodia.org

យកវត្ថុអ្វីមួយមានស្រានិងសាច់ក្លែម ឬ ប្រាក់ជាដើមតាមសមគួរ សូកអ្នកគោះត្រឡោកនោះ, បើអ្នកគោះគេសុខចិត្តព្រមបើកឲ្យទៅ ទើបចូលទៅបាន។

ល្បែងនេះ ជាល្បែងមួយយ៉ាង នាំឲ្យអ្នកទស្សនាកើតសេចក្តីរីករាយ ហើយជាល្បែងដែលរាប់ចូលក្នុងការហាត់ប្រាណ នាំឲ្យដៃកើតសាច់ដុំ នឹងឲ្យដៃរហ័សរហួន។


www.elibraryofcambodia.org

# ១៣- ល្បែងសី

**ល្បែងសី** ជាល្បែងមួយយ៉ាងសម្រាប់មនុស្សប្រុស កម្លោះ ៗ ឬ ចំណាស់ ៗ គេលេងនៅទីវាល នាពេលថ្ងៃរសៀលត្រជាក់ នៅរដូវរំហើយ ឬនៅពេលបុណ្យទានផ្សេង ៗ នាទីវត្តអារាម ។

សីមាន ៣ យ៉ាង គឺ៖

**ក- សីមីលោង**

**ខ- សីដក់**

**គ- សីពែន**

សីទាំង ៣ យ៉ាង មានប្រដាប់សម្រាប់លេងនិងរបៀបលេងប្លែកពីគ្នា ដូចរៀបរាប់តទៅនេះ៖

**ក- សីមីលោង** វត្ថុដែលគេយកមកធ្វើសីនេះ គឺគេយកបន្ទោះផ្តៅ ឬ រពាក់មកចាក់ជាក្រឡាភ្នែកក្រូច ឲ្យមានសណ្ឋានមូលប្រមាណប៉ុនត្រឡោកដូងធុនតូច ហើយគេនាំគ្នាទាត់លេង ។

សកម្មភាពនៃអ្នកលេងសីមីលោង ដូចក្នុងរូបភាពខាងមុខនេះ៖


www.elibraryofcambodia.org



អ្នកលេងសីមីលោងគេបបួលគ្នាចំនួន ៤ ឬ ៥ នាក់ ដែល គេស្ម័គ្រឲ្យមកឈរដំកង់ជារង់មូលធំ ឬ តូច តាមចំនួនមនុស្សតិច ច្រើន ។ ពេលលេងគេចែកជាគូ ៗ អ្នកណាគូនឹងអ្នកណា ត្រូវឈរ ទល់មុខអ្នកនោះ ។ មុនដំបូង អ្នកលេងម្នាក់ដែលមានសីនៅនឹង ដៃ ក៏តាំងផ្ដើមបោះសីទៅឲ្យគូរបស់ខ្លួន គូនោះក៏ទទួលទាត់ដោយ ខ្នងជើង, លុះទាត់ហើយ សីនោះក៏អណ្ដែតឡើងយ៉ាងខ្ពស់ ហើយ ធ្លាក់មកវិញ ពេលធ្លាក់នោះ ជួនក៏ចំអ្នកទាត់នោះវិញ ជួនក៏ចំអ្នក ដទៃ ហើយអ្នកដែលសីធ្លាក់មកចំនោះក៏ទទួលទាត់ឡើងភ្លាម ។ ចំណែកអ្នកឯទៀត ៗ គេត្រៀមខ្លួនចាំ ដោយសំឡឹងប្រុងប្រយ័ត្ន ភ្នែកជានិច្ច បម្រុងតែនឹងទាត់នៅពេលដែលសីធ្លាក់មកចំខ្លួន ។ ម្នាក់ ៗ ដែលសីធ្លាក់មកចំខ្លួន គេតែងស្ទុះទៅទាត់បញ្ជូនទៅឲ្យគូ


www.elibraryofcambodia.org

របស់គេ ប៉ុន្តែជួនក៏បានទៅចំគូរបស់ខ្លួន ជួនក៏ធ្លាក់ទៅចំគូរបស់អ្នកដទៃ ម្ល៉ោះហើយ គេដណ្តើមគ្នាទាត់តែរៀងខ្លួន ។

**ខ- សីដក់** គេធ្វើដោយបន្ទោះផ្តៅ ឬ រពាក់ ឲ្យមានសណ្ឋានដូចសីមីលោងដែរ ប្លែកតែសីដក់គេធ្វើឲ្យមានទំហំនិងមានក្រឡាធំជាងសីមីលោងបន្តិច ។ សីដក់មានរបៀបលេងស្រដៀងនឹងសីមីលោងដែរ ប្លែកតែសីមីលោងគេទាត់ដោយខ្នងជើង, ឯសីដក់គេគះដោយកែងដៃ ដោយក្បាលជង្គង់ ដោយស្មា និងដោយក្បាល ។

សកម្មភាពរបស់អ្នកលេងសីដក់ ដូចរូបភាពនេះ៖



**គ- សីពែន** គេធ្វើដោយស្លាបសត្វ និងស្បែក ឬ ស្រកាត្រី គឺដាក់ស្បែក ឬស្រកាត្រីត្រួតគ្នា ៣-៤ ជាន់ ចៀរជាសណ្ឋានមូលចោះចំកណ្តាល ជាប្រហោង ហើយយកស្លាបសត្វ ៤-៥ ដៃលខ្លី ៗ



www.elibraryofcambodia.org

ល្មម មកជ្រំឲ្យស្មើ រួចសិកគល់ស្លាបនោះក្នុងរន្ធស្បែក ឬស្រកាត្រី នោះឲ្យចេញមកបន្តិចហើយបត់ទៅខាង ៗ ចងដោយខ្សែល្អស ឆ្មារ ភ្ជាប់ទៅនឹងស្បែក ឬស្រកាត្រីនោះ ការពារមិនឲ្យរបូត រួចគេយកទៅទាត់ ។

សកម្មភាពរបស់អ្នកលេងសីពៃន ដូចក្នុងរូបភាព នេះ ៖



**របៀបលេងសីពៃន** គេបបួលគ្នាឲ្យបានចំនួនតាំង ពី ២ នាក់ឡើងទៅ មកឈរដំកង់ជារង្វង់មូល ទល់មុខគ្នាជាគូ ៗ គឺអ្នកណា គូនឹងអ្នកណា ត្រូវឈរទល់មុខគ្នានឹងអ្នកនោះ ។ កាលបើឈរស្រួលបួលហើយ ម្នាក់ដែលកាន់សីនៅដៃក៏បោះសីទៅឲ្យម្នាក់ទៀត ដែលជាគូរបស់គេ គូនោះក៏ទទួលទាត់ដោយបាតជើង គឺគេលើក ជើងឡើងហើយរលាស់បត់ត្រង់កជើងឲ្យបាតជើងខ្វេរ


www.elibraryofcambodia.org

ឡើងលើ ដូចគេអង្គុយពែន ទើបគេហៅថា "សីពែន"។ ពេលទាត់ គេទាត់តម្រង់ឲ្យចំសី ៗ ក៏អណ្តែតឡើង ហើយធ្លាក់ចុះមកវិញ បើធ្លាក់មកចំអ្នកណា អ្នកនោះគេទាត់បន្តឡើងទៀត, បើធ្លាក់មកចំអ្នកទាត់ដដែលវិញ អ្នកនោះក៏ទទួលទាត់វិញដែរ ។ បើសីធ្លាក់មកចំអ្នកណាហើយអ្នកនោះទទួលទាត់មិនត្រូវ ឬក៏សីនោះធ្លាក់ឆ្ងាយអំពីអ្នកលេងទាំងអស់គ្នា នាំឲ្យអ្នកលេងរត់ទៅទទួលទាត់មិនទាន់ សីក៏ធ្លាក់ដល់ដី បើធ្លាក់ក្បែរកន្លែងអ្នកណាជាងគេ អ្នកនោះគេរើសបោះទៅឲ្យគូរបស់គេ ដើម្បីឲ្យទាត់តទៅទៀត ។ ពេលដែលសីធ្លាក់មកម្តង ៗ ទាំងអស់គ្នាតែងតែសំឡឹងមើលទៅសីគ្រប់ ៗ គ្នា ក្រែងធ្លាក់មកចំខ្លួន ជួនក៏អ្នកទាំង ២ នាក់នឹកត្រូវគ្នា គឺនាក់ម្នាក់នឹកថា សីធ្លាក់មកចំខ្លួន ម្នាក់ទៀតក៏ថា ចំខ្លួនដែរ នាំឲ្យស្ទុះទៅទាត់ដណ្តើមគ្នាក៏មាន ។

ម្នាក់ ៗ ដែលសីធ្លាក់មកចំហើយ តែងតែមានចិត្តនឹកថា នឹងទាត់បង្វែរទៅឲ្យគូរបស់ខ្លួន ៗ តែជួនកាលក៏បានសម្រេច ជួនកាលក៏មិនបានសម្រេចដែរ ដោយសីនោះមិនទៅចំដូចបំណង ។

សីពែននេះ គេទាត់ ឬ គះ បានតែដោយបាតជើង, ភ្នែកគោល, កែងជើង, កែងដៃ, ក្បាលជង្គង់, ក្បាល, ស្មាប្រហែលសីដក់ដែរ តែគេហាមផ្តាច់មិនឲ្យទាត់ដោយខ្នងជើង ឬទះដោយបាតដៃឡើយ ។


www.elibraryofcambodia.org

ល្បែងសីទាំង ៣ មុខនេះ បើអ្នកលេងសុទ្ធតែប៉ិនប្រសប់ក្នុងពេលទាត់ម្តងលើក ៗ សីមិនសូវធ្លាក់ដល់ដីទេ យូរ ៗ ទើបមានធ្លាក់ដល់ដីម្តង ។

ល្បែងសី ជាកីឡាដ៏ប្រសើរមួយរបស់ខ្មែរ តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាលនេះ ក៏នៅតែមានតម្លៃនៅឡើយ ហើយជាកីឡាហាត់ប្រាណមួយ យ៉ាង ខាងកាយសម្បទាប្រហែលនឹងកីឡាបាល់ទាត់ដែរ ។


www.elibraryofcambodia.org

# ១៤- ល្បែងទាញព្រ័ត្រ

**ល្បែងទាញព្រ័ត្រ** ជាល្បែងលេងកំសាន្តសប្បាយរបស់យុវជនខ្មែរទាំងបុរស ទាំងស្ត្រី កម្លោះ ក្រមុំ ។ ល្បែងនេះ គេលេងដោយប្រើកម្លាំងកាយជាមូលហេតុ ហើយគេលេងតែនៅរដូវចូលឆ្នាំខ្មែរ គឺខែ ចែត្រ-ពិសាខ ប៉ុណ្ណោះ ។ គេច្រើននិយមលេងក្នុងវត្តអារាម ក្នុងពិធី បុណ្យចូលឆ្នាំខ្មែរ ព្រោះវត្តមានទីវាលធំទូលាយ ងាយដល់ការលេងល្បែងនេះ, តែអាចលេងនៅតាមភូមិក៏បាន បើប្រសិនជាភូមិនោះមានមនុស្សនៅផ្តុំគ្នាច្រើន ហើយមានទីវាលល្មមលេងកើត ។ ល្បែងនេះគេច្រើនលេងនៅពេលថ្ងៃ តែបើប្រសិនជាមានចង្កៀងយ៉ាងភ្លឺ ឬពន្លឺព្រះចន្ទភ្លឺថ្លាល្អ គេអាចលេងនៅពេលយប់ក៏បាន ។

**សមាសភាពនៃអ្នកលេង** ល្បែងនេះ គេចែកមនុស្សអ្នកលេងជា ២ ក្រុម ម្ខាង ៗ យ៉ាងតិចត្រឹម ៥ នាក់ ឬ ១០ នាក់ឡើងទៅតាមដែលគេរកគ្នាបានប៉ុន្មាន ក៏លេងប៉ុណ្ណោះ តែតាមទម្លាប់អ្នកស្រុក បើមានមនុស្សស្រីចូលលេងផង គេឲ្យស្រី ៗ នៅម្ខាង ប្រុស ៗ នៅម្ខាង ហើយគេយល់ថា ភេទស្រីតែងមានកម្លាំងខ្សោយជាងបុរសគេតែងដាក់ខាងស្រីឲ្យមាន ចំនួនច្រើនលើសប្រុសយ៉ាងតិច


www.elibraryofcambodia.org

ត្រឹម ២ នាក់ជាងរាប គឺបើខាងប្រុស ៨ នាក់ គេដាក់ខាងស្រី ១០ នាក់។

**គ្រឿងប្រដាប់សម្រាប់លេង** គេយកខ្សែព្រ័ត្រធ្វើពីស្បែកគោ ស្បែកក្របីធ្វើជាព្រ័ត្រ ឬគេយកពួរធ្វើពីជក់ដូងជាព្រ័ត្រ សម្រាប់ទាញ ប្រវែងយ៉ាងខ្លីពី ២០ ហត្ថឡើងទៅ ទំហំប៉ុនកដៃក្មេង ហើយនឹងយកសម្ភោរ ឬគងម៉ង់ ឬក៏រគាំង ១ សម្រាប់ទះ ឬ សម្រាប់វាយនៅពេលដែលទាញដំបូង ។

សកម្មភាពនៃអ្នកលេង ដូចក្នុងរូបភាពនេះ ៖



**របៀបលេង** មុនដំបូង គេរើសរកប្រុសម្នាក់ ស្រីម្នាក់ មានមាឌធំមាំ ស្មាគាង កម្លាំងច្រើន ឲ្យជាអ្នកឈរកាន់ចុងព្រ័ត្រ គឺប្រុសកាន់ចុងម្ខាង ស្រីកាន់ចុងម្ខាង ហើយឲ្យប្រុសម្នាក់ស្រីម្នាក់ទៀតមានមាឌធំ មានកម្លាំង ឈរកណ្ដាលព្រ័ត្រ ត្រង់កន្លែងដែលពួកទាំង ២ ឈរ សម្រាប់នាំពួកខ្លួនឲ្យខំទាញតែរៀងខ្លួន ឯមនុស្សមាឌតូចៗ ស្គមៗ កម្លាំងខ្សោយ ៗ គេឲ្យឈរកណ្ដាល គេ ។ លុះរៀបចំរួចហើយ, គេឲ្យមនុស្សប្រុសម្នាក់កាន់សម្ភោរ ឬគងម៉ង់ ឬ



www.elibraryofcambodia.org

ក៏រគាំងឈរត្រង់កណ្ដាលទីជិតអ្នកទាំងពីរដែលកាន់ខ្សែឈរប្រទល់មុខគ្នានោះ ផ្ដើមស្រែកឡើងថាយក្សអរ[១] !! ឮយ៉ាងខ្លាំង ៗធ្វើសំឡេងវែង ៗ រលាក់រលែកយ៉ាងគ្រលួច ។ ឯអ្នកប្រុងទាញព្រ័ត្រទាំងប៉ុន្មានជួយស្រែកទទួលឡើងព្រមគ្នាថា ហ៊ោរ៉ឺ ៗ ៣ ដង ទើបនាំគ្នាទាញប្រុងយកជ័យជំនះតែរៀងខ្លួន ។ ក្នុងពេលពួកអ្នកទាញព្រ័ត្រ កំពុងតែខំប្រឹងទាញ អ្នកកាន់សម្ភោរ ឬគងម៉ង់ ឬក៏រគាំង គេចេះតែបញ្ចើតសម្ភោរ ឬគងម៉ង់ ឬក៏រគាំងរឿយ ៗ ឮសូរតាក់ទីង ៗ ឬ ម៉ូង ៗ ម៉ឹង ៗ ជាដរាប ទាល់តែឃើញចាញ់ ឃើញឈ្នះម្ខាង ៗ ទើបឈប់បញ្ចើត ។

ពេលលេងម្ដងៗ អស់ថិរវេលាពី ៥-៦ នាទី ដល់ ១០ នាទីឡើងទៅ ទើបឃើញឈ្នះ ឃើញចាញ់ម្ខាង ៗ ។

កាលដឹងថាខាងណាឈ្នះខាងណាចាញ់ហើយ គេចាប់ផ្ដើមលេងសាជាថ្មីតទៅទៀត ដរាបដល់ហត់តែរៀងខ្លួន ទើបឈប់ ។

ល្បែងនេះ ចាត់ទុកជាការហាត់កម្លាំង ហាត់ប្រាណ ឲ្យរាងកាយមានកម្លាំង មានសុខភាពល្អ ។

---

[១] ពាក្យ យក្សអរនេះ អ្នកស្រុកតែងហៅថា ឆាកទុម្ពា គេទុកជាពាក្យប្ដើម សម្រាប់ប្រើស្រែកក្នុងពិធីផ្សេង ៗ មានការទាញព្រ័ត្រ ឬ ការសែងទូកចុះចាកបង្គង ឬ ក៏លើកដាក់លើបង្គង ជាដើម ។



www.elibraryofcambodia.org

# ១៥- ល្បែងកូនគោល

**ល្បែងកូនគោល** *អ្នកស្រុកខ្លះគេហៅ "ល្បែងប្រដំ" ជាល្បែងរបស់មនុស្សកម្លោះ ក្រមុំ ឬ ក្មេងជំទង់ តែងលេងនៅពេលទំនេរនាររដូវប្រាំង ឬ រដូវចូលឆ្នាំ ។*

**ប្រដាប់លេង** មាន ២ មុខ គឺ ដំបង ឬ ទំពក់សម្រាប់វាយ ឬប្រដំមួយមុខ កូនគោល ឬ កូនប្រដំ ១ មុខ ។ ដំបង ឬ ទំពក់គេធ្វើពីគល់ឬស្សីព្រៃច ឬ គល់ពីងពង់ ទំហំប៉ុនកដៃក្មេង មានដងស្រលួតគល់ក្រងក់ ។ កូនគោល ឬ កូនប្រដំ គេធ្វើពីឈើសាច់ស្តោត ៗ ស្រាល ៗ មានឈើរលួស ឬ គរជាដើម ។

កូនគោល ឬកូនប្រដំ មាន ២ បែប ៖ ១ បែបសម្រាប់លេងក្នុងវេលាថ្ងៃ ១ បែបទៀតសម្រាប់លេងក្នុងវេលាយប់ ។ បើលេងវេលាថ្ងៃ គេយកឈើរលួស ឬគរមកកាត់ជាកង់ ៗ ហើយលុបជ្រុងធ្វើឲ្យមូល ហាលថ្ងៃឲ្យស្ងួត ហើយយកទៅវាយលេង ។ បើលេងវេលាយប់ គេយកឈើរលួស ឬ គរដែលកាត់ជាកង់ ៗ នោះ ដុតភ្លើងឲ្យឆេះចេញរងើក ហើយយកទៅវាយលេង ឲ្យមើលទៅឃើញភ្លឺក្រហមឆ្អៅ ឆ្លោចុះឆ្លោឡើង តាមរយៈដែលវាយទៅមក ។ កូនគោលភ្លើង ស្រុកខ្លះគេលេងជាការកំសាន្ត ស្រុកខ្លះគេលេងជា



www.elibraryofcambodia.org

ការបណ្ដេញខ្មោចបិសាច ក្នុងពេលស្រុកកើតជម្ងឺ ។

ទីកន្លែងលេង គេច្រើនយកទីដីវាលស្រែ ឬចម្ការ ដែលមានទំហំធំទូលាយ ស្អាតល្អ ឬបើមានផ្លូវថ្នល់ធំវែងទូលាយជាទីស្ងាត់ជួនកាលគេក៏យកជាទីលេងខ្លះដែរ ។

ល្បែងនេះ គេចែកមនុស្សអ្នកលេងជា ២ ពួក មានចំនួនស្មើគ្នា យ៉ាងតិចពី ២ ឬ ៤ នាក់ឡើងទៅ បើអ្នកលេងមានប្រុសផង ស្រីផង ប្រុសលេងជាមួយប្រុសក៏បាន, ស្រីលេងជាមួយស្រីក៏បាន ស្រីម្ខាងប្រុសម្ខាងលេងជាមួយគ្នាក៏បាន ។ ពេលលេង គេគូសដីចំកណ្ដាលទីជាស្នាម ហើយគេយកភ្លឺស្រែ ឬចម្ការ ឬក៏ដោតតម្រុយម្ខាង ៗ ខាងឆ្វេងដៃរបស់គេធ្វើជាគ្រឿងចំណាំបើអ្នកលេងសុទ្ធតែប្រុស គេឲ្យប្រុស ២ នាក់ ឈរចំស្នាមនោះ បើអ្នកលេងសុទ្ធតែស្រី គេឲ្យស្រី ២ នាក់ឈរចំស្នាមនោះ, បើអ្នកលេងស្រីម្ខាងប្រុសម្ខាង គេឲ្យប្រុសម្នាក់ ស្រីម្នាក់ឈរចំស្នាមនោះ បែរមុខរកគ្នា ហើយបណ្ដាអ្នកទាំង ២ នោះម្នាក់កាន់កូនគោល ឬកូនប្រដំមកដាក់ត្រង់កណ្ដាលស្នាមគូសនោះ ទើបអ្នកទាំង ២ នោះគេកាន់ចុងដំបង ឬទំពក់ ១ ម្នាក់ លើកគល់ឡើងប្រទាស់គ្នាហៅថា " កៃ " គឺវាយលៗផ្លាស់ប្ដូរគ្នា ពីស្ដាំទៅឆ្វេង ពីឆ្វេងទៅស្ដាំ ចំនួន ៣ ដង ហើយអ្នកកៃទាំង ២ នាក់នោះ សុទ្ធតែលួចល្បក់គ្នាវាយកូនគោលឬកូនប្រដំនោះ ពីស្ដាំទៅឆ្វេងរបស់ខ្លួន ដើម្បីឲ្យកូនគោល ឬ


www.elibraryofcambodia.org

កូនប្រដំនោះរត់ទៅកាន់ទីខាងឆ្វេងជានិច្ច ដែលគេទុកជាទីរបស់គេរៀងខ្លួន ។

សកម្មភាពរបស់អ្នកលេង ដូចក្នុងរូបភាពនេះ ៖



ល្បែងនេះមានប្រណាមតឹងណាស់ គឺពេលកំពុងប្រយុទ្ធដណ្តើមកូនគោល ឬ កូនប្រដំគ្នា គេតមមិនឲ្យអ្នកវាយទាំងសងខាងយកដៃចាប់កូនគោលឬកូន ប្រដំនោះបោះទៅទីរបស់ខ្លួនទេ គ្រាន់តែទាត់នឹងជើងបាន បើខាងណាម្នាក់យកដៃចាប់កូនគោល ឬកូនប្រដំ គេទុកការនោះជាអសារបង់ ត្រូវយកកូនគោល ឬកូនប្រដំទៅកែសាជាថ្មី ។ មួយទៀត គេតមមិនឲ្យអ្នកវាយទាំងសងខាងឈរ ឬរត់ទៅដណ្តើមយកកូនដល់ទីទេ ត្រណាមខាងក្រោយនេះ អ្នកលេងគេប្រយ័ត្នណាស់ ព្រោះដើរខុសត្រណាមនេះរមែងមានគ្រោះថ្នាក់ ។

ល្បែងនេះ គេយកចាញ់ឈ្នះគ្នា ត្រង់ការដែលគូប្រយុទ្ធ


www.elibraryofcambodia.org

ដណ្ដើមវាយកូនគោលឬកូនប្រដំ ឲ្យចូលទៅដល់ចុងទីរបស់ខ្លួនបាន ។ បើខាងណាគេវាយកូនគោល ឬកូនប្រដំឲ្យចូលទីខាងគេបាន ឈ្មោះថាគេមានជ័យជំនះ ហើយគេលេងសារឡើងជាថ្មី ត្រាតែដល់ពេលឈប់លេង ទើបគេយកចំនួនលើកដែលឈ្នះចាញ់នោះមកគិតមើល ឲ្យដឹងថាខាងណាឈ្នះប៉ុន្មានលើក ខាងណាចាញ់ប៉ុន្មានលើក គឺឈ្នះប៉ុន្មានទល់នឹងចាញ់ប៉ុន្មាន តែគ្រាន់តែជាកិត្តិយស ឥតមានស៊ីសងជាវត្ថុអ្វីទេ ។

តាមសេចក្ដីឲ្យការណ៍ខ្លះថា ល្បែងនេះនៅស្រុកខ្លះ គេយកស្រកីដូងមកធ្វូលចងឲ្យមូលធ្វើជាកូនគោល ហើយគេទាត់ដោយជើង ។ របៀបយកចាញ់យកឈ្នះ ប្រហែលគ្នានឹងកូនគោលឈើដែលវាយដោយដំបងនោះដែរ ។

ល្បែងនេះ ជាល្បែងរបស់ខ្មែរសម័យបុរាណ ដែលរាប់ចូលក្នុងពួកកីឡាបាល់ទាត់ បាល់បោះ បាល់- ទះ កូនឃ្លី ក្នុងសម័យបច្ចុប្បន្ននេះបាន ។


www.elibraryofcambodia.org

# ១៦- ល្បែងរាវបង្គង

**ល្បែងរាវបង្គង**[១] ជាល្បែងមួយយ៉ាង សម្រាប់លេងកំសាន្តសប្បាយនៃពួកកុមារាកុមារីតូច ៗ ឬ ជំទង់ ៗ ។ គេលេងនៅពេលរាត្រីខែភ្លឺក៏បាន ពេលថ្ងៃក៏បាន ចំនួនអ្នកលេងមិនកំណត់ ។

សកម្មភាពរបស់អ្នកលេង ដូចក្នុងរូបភាពនេះ ៖



**មុននឹងលេង** គេបបួលពួកកុមារាកុមារីឲ្យបានច្រើនគ្នា ។ គេយកក្រមាឬកន្សែងចងខ្ទប់ភ្នែកកុមារ ២ នាក់ឲ្យជិត ហើយគេលែងកុមារទាំង ២ នាក់នេះឲ្យដើររាវរកចាប់គ្នា ។ បណ្តាអ្នកទាំង ២ នេះ គេឲ្យម្នាក់កាន់បំពង់ឬស្សី ឬ ត្រឡោកដូងក៏បាន ដើរគោះត្រង់នេះ ១ ប៉ូក ត្រង់នោះ ១ ប៉ូក ពេលដែលគោះហើយ អ្នកគោះ

[១]- ស្រុកខ្លះហៅថា ល្បែងអាខ្វាក់អាខ្វិន របៀបលេងប្រហែលគ្នា ៗ



www.elibraryofcambodia.org

នោះ ត្រូវគេចខ្លួនឲ្យរហ័សដោយកុំឲ្យឮស្នូរជើង ។ ចំណែកម្នាក់ទៀត ជាអ្នករាវរកចាប់អ្នកគោះបំពង់ឬស្សី ឬត្រឡោកដូងនោះ កាលណាឮស្នូរសំឡេងគេគោះត្រង់ណា អ្នករាវក៏ស្ទុះទៅស្រវាឱប ដោយស្មាននៅកន្លែងនោះ ឬកន្លែងក្បែរៗនោះ ស្រេចតែកលល្បិចរបស់ខ្លួនយ៉ាងណា ឲ្យតែចាប់អ្នកគោះបាន ។ បើអ្នករាវគេប៉ិនស្តាប់ស្នូរជើងដើរ គេក៏ស្ទុះទៅឱបស្មាន ៗ ត្រង់កន្លែងស្នូរជើងនោះ ជួនក៏រាវចាប់បាន ជួនក៏មិនបាន ។ បើកាលណាអ្នករាវរកចាប់មិនបាន គេទុកអ្នកគោះត្រឡោកនោះជាឈ្នះ បើអ្នករាវចាប់បាន គេឲ្យអ្នករាវធ្វើជាអ្នកគោះត្រឡោកវិញម្តង គេលេងតែរបៀបនេះរហូតដល់ពេលឈប់លេង ឯអ្នកណាជាអ្នកគោះត្រឡោកមុន ឬជាអ្នករាវរកមុននោះ ពុំកំណត់ទេ ស្រេចលើការព្រមព្រៀងគ្នា ។

ល្បែងនេះ ជាការហាត់ត្រចៀកឲ្យស្ទាត់ក្នុងការស្តាប់សម្លេង និង ឲ្យមានស្មារតីរឹងប៉ឹងរហ័សដៃ-ជើង ។


www.elibraryofcambodia.org

# ១៧- ល្បែងចោះប្រមាត់

**ល្បែងចោះប្រមាត់** ជាល្បែងដែលមានតែនៅភូមិកំពង់ភ្លុក, ភូមិកំពង់ឃ្លាំង ស្រុកសូទ្រនិគម និង ស្រុកជីក្រែង ខេត្តសៀមរាប ជាភូមិនៅមាត់ទន្លេសាប ។ អ្នកស្រុកទាំងនេះគេតែងលេងល្បែងនេះប្លែកពីស្រុកឯទៀត ។

ល្បែងនេះ គេលេងតែក្នុងរដូវវស្សា តាំងពីពេលដាក់បិណ្ឌ ទៅទល់នឹងថ្ងៃចេញវស្សា គឺពីថ្ងៃ ១ រោច ខែភទ្របទ ទៅទល់នឹងថ្ងៃ ១៥ កើត ខែកត្តិក រៀងរាល់ឆ្នាំ ។

**របៀបលេង** មានទូកពីរ, ១ សម្រាប់ដេញ សុទ្ធតែប្រុស, ១ សម្រាប់រត់សុទ្ធតែស្រី ទំហំនឹងចំណុះទូកស្មើគ្នា ហើយចំណុះមានកំរិតត្រឹមពី ៨ នាក់ទៅ ១០ នាក់យ៉ាងច្រើន ។ បើមានអ្នកលេងច្រើនគេផ្គូទូកជាគូ ៗ ទូកប្រុស ១ ទូកស្រី ១ ជាមួយគ្នា ។

សកម្មភាពរបស់អ្នកលេង ដូចក្នុងរូបភាពខាងមុខនេះ ៖




www.elibraryofcambodia.org

គេលេងល្បែងនេះ ក្នុងទីដែលមានទឹករាក់ ៗ ជម្រៅត្រឹមក ឬលិចក្បាល ។ ពេលផ្ដើមលេង អ្នកលេងទាំងពីរពួក គេចុះទូក ពេញ ៗ ចំណុះតែរៀងខ្លួន ហើយទូកខាងប្រុសធ្វើជារអុំលេង ៗទៅ រកទូកខាងស្រីណាដែលជាគូនឹងទូកខ្លួន លុះខាងប្រុសអុំលេង ៗ ទៅជិតទូកខាងស្រី ប្រុស ៗ ស្រែកសួរថា " ចោះប្រមាត់ ? " ស្រីៗ ជួនកាលឆ្លើយថា " ចោះក៏ចោះ " ជួនកាលឆ្លើយថា "ទេ" ជួនកាល ឥតឆ្លើយតប ។ ឯខាងប្រុសទោះបានឮពាក្យថា ព្រមក្ដី មិនព្រមក្ដី ឬស្ងៀមក្ដី ក៏ស្រែកព្រមគ្នាថា "ដេញៗ" ឮតែប៉ុណ្ណោះ ខាងស្រីក៏អុំ ទូករត់ ខាងប្រុសក៏ប្រឹងអុំតាម ។ ការដេញតាមនោះ ជួនកាលទាន់ ជួនកាលទេ ស្រេចលើកម្លាំងរៀងខ្លួន បើខាងប្រុសដេញទាន់ ក៏គេ លោតទៅតោងទាញទូកខាងស្រីឲ្យលិច ហៅលព្រាតព្រោង ។ ពេលនោះខាងស្រី ៗ ឥតមានប្រកាន់ខ្លួនឡើយ គេចេះតែប្រឡែង ប្រឡូកគ្នាក្នុងទឹក ប្រុស ៗ ដេញញៀចស្រី ៗ ត្រាតែអស់ចិត្តអស់ ថ្លើម ហត់រៀងខ្លួន ទើបគេនាំគ្នាស្ដារទូកឡើង ហើយគេនាំគ្នាអុំ លេងតទៅទៀតសារជាថ្មី កាលដេញទាន់ពន្លិចបាន គេញៀចគ្នា ជាថ្មីទៀត ។ បើលេងពេលព្រឹកត្រាតែដល់ពេលបាយ បើលេង ពេលយប់ ត្រាតែពាក់កណ្ដាលអធ្រាត្រ ,ទើបខាងប្រុសគេបើកឲ្យ ខាងស្រីទៅផ្ទះរៀង ខ្លួន ។

ល្បែងនេះ ជាទំនៀមរបស់អ្នកស្រុក ដូចមាន ឈ្មោះខាង


www.elibraryofcambodia.org

លើ គេលេងដោយស្មោះត្រង់ ឥតមានប្រកាន់ថាខុសត្រូវអ្វីឡើយ គិតតែនាំគ្នារីករាយសប្បាយជាកំសាន្តមួយយ៉ាងប៉ុណ្ណោះ។

**ល្បែងនេះ រាប់ចូលក្នុងការហាត់ប្រាណ ហាត់កម្លាំងឲ្យរាងកាយឡើងសាច់ដុំមានសុខភាពល្អ ប្រហាក់ប្រហែលគ្នានឹងកីឡាហែលទឹកសព្វថ្ងៃនេះដែរ ។**



www.elibraryofcambodia.org

# ១៨- ល្បែងបាយខុំ

ល្បែងបាយខុំ ជាល្បែងមួយ យ៉ាងដែលអ្នកស្រុកគ្រប់ជនបទក្នុងប្រទេសកម្ពុជាទាំងមូល គេតែងលេងកំសាន្តនៅពេលទំនេរម្តងម្កាល ។

របៀបលេង នឹងសម្ភារៈសម្រាប់លេង គេជីកដីជារណ្តៅតូច ៗ ឬគេយកចានតូច ៗ ឬគេចោះក្តារ ១ បន្ទះធំឲ្យមានជម្រៅចំនួន ៣ ឬ ៤ សង់ទីម៉ែត្រម៉ែត្រ ធ្វើជារន្ធ ១០ ដាក់គ្រាប់សម្រាប់លេង ។ បណ្តារន្ធទាំងនោះ រន្ធធ្វើពីឈើ ឬចានស្រួលលេងជាងគេ ព្រោះលេងហើយគេអាចយកទៅប្រើទីណាក៏បានឬគេទុកលេងថ្ងៃក្រោយទៀតក៏បាន ។ រន្ធទាំងនេះគេធ្វើជា ២ ជួរ ១ ជួរ ៥ ៗ ឲ្យមានសណ្ឋានដូចពងក្រពើ ។ បណ្តារន្ធទាំង ២ ជួរនោះ ក្នុងមួយជួរ មានរន្ធ ១ ខាងដើមជាមេ ហៅថារន្ធក្បាលជីមឿង ។ លុះធ្វើហើយគេយកវត្ថុដែលមានដុំតូច ៗ ដូចជាគ្រាប់ចម្បក់ គ្រាប់អម្ពិល សំបកខ្ចៅ ឬផ្លែកន្ទួតស្រុក កន្ទួតព្រៃជាដើម ដែលអ្នកផងនិយមយកមកលេងជាងគេនោះ ច្រើនតែគ្រាប់អម្ពិល[១] ឬក្រួសតូច ៗ ព្រោះជារបស់ស្ងួតស្រួលលេង ។ ក្នុងរន្ធទាំង ១០ នោះ រន្ធក្បាលជីមឿងត្រូវ

---

[១]- តាមទម្លាប់ស្រុកខ្លះ សន្មតហៅគ្រាប់នេះថា ដៀប ៗ



www.elibraryofcambodia.org

ដាក់គ្រាប់ ៥ ក្រៅពីនោះដាក់តែ ៤ គ្រាប់ ៗ ស្មើគ្នារួមទាំងអស់ត្រូវជា ៥២ គ្រាប់ ។

**ពេលលេង** អ្នកលេងទាំង ២ នាក់ អង្គុយទល់មុខគ្នាម្ខាងម្នាក់រន្ធបាយខុំជនៅជាកណ្ដាល ។ ឯរន្ធក្បាល ជីមឿង ត្រូវនៅខាងស្ដាំដៃរៀងខ្លួន[២] ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



កាលបើដាក់គ្រាប់ហើយគេឲ្យម្នាក់ចាប់ផ្ដើមដើរគ្រាប់មុន[១] អ្នកដើរគេចាប់យកគ្រាប់ដោយដៃស្ដាំ អំពីរន្ធណាមួយខាងស្រុករបស់ខ្លួន ដាក់ ១ គ្រាប់ទៅក្នុងរន្ធ ឬចានខាងស្ដាំ ឬខាងឆ្វេងបន្ទាប់ពីរន្ធ ឬចានដែលខ្លួនបានចាប់ពីដំបូងនោះ ។ ដាក់គ្រាប់ ១ ទៅក្នុង

---

២- តាមនិយមស្រុកខ្លះ ស្រេចនៅលើសន្មតគ្នាជាមុន ថាយកខាងឆ្វេង ឬខាងស្ដាំ ។

១- ជួនកាលគេដើរញែកគ្រាប់ គឺមុននឹងដើរទៅស្ដាំ ត្រូវដាក់មួយគ្រាប់មករន្ធខាងឆ្វេងសិន ។



www.elibraryofcambodia.org

រន្ធ ឬចាននោះ ហើយដាក់គ្រាប់ ១ ទៀតទៅក្នុងរន្ធឬចានបន្ទាប់ ដែលនៅជិតគ្នានោះតទៅទៀត ដាក់ ១ រន្ធ ១ គ្រាប់ ៗ ទាល់តែ អស់គ្រាប់ ដែកាន់នៅដៃ ។ កាលបើអស់គ្រាប់នៅក្នុងដៃត្រង់រន្ធ ណា ទើបគេចាប់យកគ្រាប់ពីរន្ធបន្ទាប់នោះរាយតទៅទៀត បើ អស់គ្រាប់ត្រង់រន្ធណាមួយហើយ ឃើញរន្ធ ១ បន្ទាប់នោះទទេ គេ លូកកិះរន្ធនោះ ហើយគេចាប់យកគ្រាប់ក្នុងរន្ធបន្ទាប់នោះលើក ឡើងយកមកទុកនៅមុខគេ ហៅថាស៊ី តែបើស៊ីចំរន្ធណាដែល មានរន្ធទទេតទៅទៀត គេអាចកិះស៊ីបន្តទៅទៀត ទោះជា ២ ដំណា ៣ ដំណាក៏ដោយ ។ បើដើររាយគ្រាប់ទៅអស់ត្រង់រន្ធណា ហើយរន្ធបន្ទាប់នោះគ្មានគ្រាប់ដល់ទៅ ២ រន្ធ នោះគេហៅថា ឃ្វាង ឥតបានស៊ីទេ បើដើររាយគ្រាប់ទៅ អស់ត្រង់រន្ធណា ហើយរន្ធបន្ទាប់នោះ ឥតមានគ្រាប់ រន្ធបន្ទាប់មកទៀតមាន គ្រាប់តែ ១ នោះ គេហៅថា ស៊ីម៉ង់ គឺស៊ីបានតែមួយ ម៉ង់ ៗ ។

របៀបចាញ់ឈ្នះនោះ គឺអ្នកម្ខាងស៊ីអស់អ្នកម្ខាងរកគ្រាប់ ដាក់រន្ធខ្លួនពុំបាន កាលបើដូច្នេះ អ្នកឈ្នះយកគ្រាប់ ២១ ដាក់ទៅ ក្នុងរន្ធ ១ ម្តង ៗ ឲ្យអ្នកចាញ់ផ្លុំបញ្ចេញពីរន្ធ ឬដាក់លើមាត់រន្ធឲ្យ អ្នកចាញ់ផ្លុំបញ្ចូល ឲ្យទាល់តែអស់គ្រាប់ទាំង ២១ នោះ បើផ្លុំមិន ចេញ ឬមិនចូលអស់ទេ គេដោះក្បាលជង្គង់អ្នកចាញ់ ២១ ដៃទើប គេចាប់លេងតទៅទៀត ។


www.elibraryofcambodia.org

ល្បែងបាយខុំ ជាល្បែងមួយយ៉ាងអាចរាប់ចូលក្នុងការហាត់គំនិតខាងគិតលេខ និងការល្បិចវាងវៃក្នុងស្មារតី ចំពោះរបៀបលៃលករកចំណេញ ឲ្យឃើញទៅពេលខាងមុខវែងឆ្ងាយជាមុន ។


www.elibraryofcambodia.org

# ១៩- ល្បែងលាក់កូនកាស

**ល្បែងលាក់កូនកាស** ជាល្បែងមួយយ៉ាង សម្រាប់ក្មេងជំទង់ ៗ លេងកំសាន្តសប្បាយ ។ ល្បែងនេះ គេលេងបានតែនៅក្នុងទឹករអូរ ឬទន្លេដែលមានជម្រៅត្រឹមចង្កេះ ឬត្រឹមដើមទ្រូងក្មេង ៗ អ្នកត្រូវការលេងនោះ ៗ ។

**របៀបលេង** ក្មេងៗបបួលគ្នាឲ្យបាន ៤-៥ នាក់ឡើងទៅ គេចុះទៅក្នុងទឹកជម្រៅដូចពោលខាងលើ ហើយយកកំណាត់ឈើ ឬដើមស្មោរខ្ចី ៗ ដែលជាវត្ថុស្រាល ៗ អណ្តែតទឹក ធ្វើជាខ្នាច់ដាក់បណ្តែតលើខ្នងទឹក បង្ហាញអ្នកលេងទាំងអស់គ្នា ឲ្យឃើញច្បាស់នឹងភ្នែកថានេះ ជា " កូនកាស " កុំឲ្យច្រឡំនឹងកំណាត់ឈើឯទៀត, ហើយអ្នកលេងទាំងអស់គ្នា គេនាំគ្នារើសកំណាត់ឈើផ្សេង ៗ ដែលមាននៅក្នុងទឹកត្រង់កន្លែងលេងនោះចេញអស់ ដើម្បីកុំឲ្យច្រឡំ នឹងកូនកាសរបស់ខ្លួន ហើយគេនាំគ្នាឈរជំកង់ជាវង់ក្នុងទឹកដាក់ខ្នាច់ជាកូនកាសនៅចំកណ្តាលវង់ ។

សកម្មភាពនៃអ្នកលេង ដូចក្នុងរូបភាពខាងមុខនេះ ៖


www.elibraryofcambodia.org



លុះរៀបស្រួលបួលហើយ គេនាំគ្នាបញ្ច្រោកទឹកពន្លិច ឬបន្សាត់កូនកាសចេញហើយឈប់បង្អង់បន្តិច ទើបនាំគ្នាគន់រកមើលខ្នាច់ ដែលអណ្តែតឡើង ហើយរសាត់ឆ្ងាយពីខ្លួន បើអ្នកណារកឃើញមុនគេ[១] ហើយចាប់យកខ្នាត់នោះបានអ្នកនោះត្រូវដេញញៀចស្លឹកត្រចៀក គឺ មួលស្លឹកត្រចៀកអ្នកទាំងអស់គ្នា ដែលរកពុំឃើញ ។ មុននឹងទៅដេញចាប់ញៀចគេនោះ អ្នកបានខ្នាច់នោះគេស្រែកជាសញ្ញាថា " ញៀច " ។ ពេលនោះ បើអ្នកណាមុជទឹកទាន់ អ្នកនោះត្រូវរួចខ្លួន អ្នកដេញញៀចមិនត្រូវញៀចគេទេ ។

ល្បែងនេះ ជាល្បែងមួយ សម្រាប់លេងជាកំសាន្តផង សម្រាប់ហាត់ភ្នែកឲ្យរហ័សឲ្យវៃ ក្នុងការពិនិត្យរកវត្ថុអ្វីផ្សេងៗ នឹងជាកីឡាហែលទឹក គឺការហាត់ហែលទៀតផង ។

[១]- អ្នកស្រុកខ្លះគេលេងកញ្ច្រោកដណ្តើមយកក្នុងពេលនោះតែម្តង មិនបាច់ឈប់បង្អង់ទេ ។



www.elibraryofcambodia.org

# ២០- ល្បែងលាក់ធ្យូង

**ល្បែងលាក់ធ្យូង** ជាល្បែងសម្រាប់ក្មេងប្រុស ឬស្រីជំទង់ ៗ តែប្រុសសុទ្ធតែប្រុស ស្រីសុទ្ធតែស្រី លេងកំសាន្តនៅពេលទំនេរ, គេលេងតែពេលថ្ងៃ នៅក្រោមម្លប់ឈើ ឬទីវាលពេលមេឃស្រទំក៏បាន ។

សមាសភាពនៃអ្នកលេង មានគ្នាយ៉ាងតិចត្រឹម ៥នាក់ឡើងទៅ ។

សកម្មភាពនៃអ្នកលេង ដូចក្នុងរូបភាពនេះ ៖



**មុននឹងលេង** គេបបួលគ្នា ២ នាក់ អង្គុយសណ្ដោកជើងទាំង ២ ជាជួរទន្ទឹមគ្នា ផ្កាប់បាតដៃទាំង ២ ឬក្ដោបដាក់លើក្បាលជង្គង់ទាំង ២ ។ មានក្មេង ៥ នាក់ទៀតមិនអង្គុយសណ្ដោកជើងទេ គេឲ្យម្នាក់កាន់ធ្យូងរឹង ១ ដុំតូចល្មម ឬដុំក្រួសក៏បាន ដើរចាប់បើកបាត


www.elibraryofcambodia.org

# ២១- ល្បែងប៉ក់ចាប

**ល្បែងប៉ក់ចាប** ជាល្បែងខ្មែរមួយយ៉ាង លេងដោយកុមារាកុមារីជំទង់ៗ ឬកម្លោះក្រមុំក៏អាចលេងបាន តែគេច្រើនលេងដោយពួកៗ គឺប្រុសសុទ្ធតែប្រុស ស្រីសុទ្ធតែស្រី ហើយគេលេងនៅពេលណាក៏បានតែច្រើនតែពួកក្មេងៗ គង្វាលគា-ក្របី ដែលដេញហ្វូងគោក្របី របស់ខ្លួនទៅស៊ីស្មៅនៅវាលស្រែ..ពេលព្រឹក ឬល្ងាច ហើយលេងកំសាន្តសប្បាយនៅក្រោមម្លប់ឈើ ក្នុងពេលដែលក្របីគោរបស់ខ្លួនកំពុងស៊ីស្មៅយ៉ាងស្ងៀមស្ងាត់ ។

**របៀបលេង** ដំបូងគេបបួលគ្នាអោយបានចាប់ពី ២ នាក់ឡើងទៅគេរកគ្រាប់ក្រួសអោយបាន ៥ឬ១០គ្រាប់ក្នុងម្នាក់ៗ តែចំនួនគ្រាប់នេះ មិនកំណត់ជា ៥ឬ១០នោះទេ ស្រេចតែអ្នកលេងទាំងសងខាងព្រមព្រៀងកំណត់គ្នាជាមុន ។ តែតាមធម្មតា គេច្រើនតែកំណត់ត្រឹម ៥គ្រាប់ម្នាក់ប៉ុណ្ណោះ ។ ល្បែងនេះគេលេងដោយចាត់ជាថ្នាក់ៗ គឺលាក់, ទាយ, ប៉ក់, រកឈ្នះចាញ់ ។

ក្នុងទីនេះ និយាយចំពោះតែអ្នកលេង ២នាក់ នឹងគ្រាបសម្រាប់លេង ៥គ្រាប់ម្នាក់ ដើម្បីអោយងាយយល់តាមលំដាប់ថ្នាក់ដូចតទៅ៖

សកម្មភាពនៃអ្នកលេង ដូចរូបភាពនេះ


www.elibraryofcambodia.org



**ថ្នាក់ទី១-លាក់** កាលគេរកគ្នាជាអ្នកលេង និងគ្រាប់ សម្រាប់លេងបានហើយ គេអង្គុយទល់មុខគ្នា ដៃម្ខាងក្ដាប់គ្រាប់ក្រួស ដៃម្ខាងទុកអោយនៅទំនេរគ្រប់គ្នា ។ គេលាក់គ្រាប់ ក្រួសនោះដោយដាក់ ដៃទាំង ២មកខាងក្រោយខ្នងទាំងអស់គ្នា ហើយបន្លេចគ្រាប់ក្រួសមកដាក់ខាងដៃទទេ (ដាក់ប៉ុន្មានក៏ស្រេចតែចិត្ត របស់ខ្លួនគ្រប់គ្នា) ដោយប្រុងប្រយ័ត្ន កុំអោយអ្នកលេងទាំងអស់គ្នាដឹង, ចំណែកដៃដែល ដាក់គ្រាប់ថ្មីនេះ ក៏គេក្ដាប់អោយជិតមកដាក់ពីមុខរៀងខ្លួន ។

**ថ្នាក់ទី២-ទាយ** កាលលាក់រួចស្រេចគ្រប់គ្នាអស់ហើយ គេក៏ចាប់ទាយ, ឧបមាថា អ្នកទី ១ទាយថា៣,អ្នកទី២ទាយថា៥ រួចហើយគេបើកដៃក្ដាប់នោះទាំងអស់គ្នាឡើង រាប់គ្រាប់មើលទាំងអស់ គ្នា ឃើញអ្នកទី១ដាក់-១គ្រាប់ អ្នកទី២ដាក់-៣គ្រាប់ រួមចំនួនគ្រាប់ ដៃលាក់ទាំង២នាក់ ត្រូវចាប់ផ្ដើមលាក់សាជាថ្មីម្ដងទៀត ហើយ ទាយដូចមុន ។ ប្រសិនបើអ្នកទី១ទាយថា៥ អ្នកទី២


www.elibraryofcambodia.org

ទាយថា៣ លុះបើក ដៃឡើងឃើញអ្នកទី១ដាក់ទី២ អ្នកទី២ដាក់ទី៣ រួមគ្រាប់ ទាំង២នាក់ ត្រូវជា៥ដូច្នេះ ការនេះឈ្មោះថាអ្នកទី១ ត្រូវប្រមូល គ្រាប់ទាំងអស់ពីអ្នកទី២មកដាក់បញ្ចូលគ្នាជាមួយនឹងគ្រាប់របស់ខ្លួន ទាំងអស់ ។

**ថ្នាក់ទី៣-ប៉ក់** អ្នកប៉ក់ទី ១ដាក់គ្រាប់ទាំងអស់ ក្នុងកំបង់ដៃម្ខាងហើយលើកគ្រាប់ទាំងអស់នោះចោះទៅលើបន្តិច ដោយដៃម្ខាង[1]ថ្នមៗ កុំអោយគ្រាប់បាចសាចរាយប៉ាយរួចត្រឡប់ត្រងគ្រាប់ទាំងអស់ ដោយខ្នងដៃ ឧបមាថាត្រងបាន៤គ្រាប់ ហើយលើកគ្រាប់៤នោះបោះទៅលើម្តងទៀត រួចត្រឡប់ត្រងចាប់ ខាងបាតដៃវិញ មេចាប់បានមិនជ្រុះឈ្មោះថា បាន៤គ្រាប់នោះ បើត្រឡប់ចាប់ខាងបាតដៃនោះ មានជ្រុះខ្លះគេហៅថា "ក្អួត" អ្នកប៉ក់ទី១ នោះត្រូវបាន គ្រាប់អ្វីបន្តិចបន្តួចទេ ត្រូវប្រគល់ គ្រាប់ទាំងអស់ទៅអ្នកទី២ ក៏ត្រូវចាប់ផ្តើមប៉ក់ដូចអ្នកទី១ ដែរ ឧបមាថាបើអ្នកទី២ នេះប៉ក់ទៅ គ្មានក្អួតបាន ៣គ្រាប់នោះ គ្រាប់ត្រូវនៅសល់តែ៧ទេ អ្នកទី១ ក៏ប្រមូលគ្រាប់ទាំង៧នេះ ទៅប៉ក់ទៀត ឧបមាថាបាន៤គ្រាប់ ដូច្នេះគ្រាប់ត្រូវសល់តែ៣អ្នកទី២យកគ្រាប់ទាំង៣នេះ ទៅប៉ក់ឧបមាថាអ្នកទីពីរប៉ក់បានទាំង៣គ្រាប់នេះតែម្តងដូច្នេះឃើញថាអស់គ្រាប់ហើយ ។

[1] បើគេបានសន្យាគ្នាថាលេងប៉ក់ដៃ ទើបគេប៉ក់ដៃពីរ បើសន្យាគ្នាថាប៉ក់តែ១ប៉ក់ដៃ១ទៅ



www.elibraryofcambodia.org

**ថ្នាក់ទី ៤-រកឈ្នះចាញ់** អម្បាញមិញនេះ អ្នកលេងទាំងពីរនាក់ គឺអ្នកទី១ប៉ក់បានតែ៤គ្រាប់ ឯអ្នកទី២ ប៉ក់បានដល់ ទៅ៦ គ្រាប់ ដូច្នេះអ្នកទី១ត្រូវខ្វះ១គ្រាប់ អ្នកទី២ ប៉ក់បានដល់ ទៅ៦ គ្រាប់ ដូច្នេះអ្នកទី១ត្រូវខ្វះ១គ្រាប់ អ្នកទី២ លើស១គ្រាប់ ហើយអ្នក ទី១ ត្រូវខ្ចីពីអ្នកទីពីរមួយគ្រាប់ ដើម្បីអោយបានគ្រប់ជា ៥គ្រាប់ដូច ដែលបានកំណត់ពីខាងដើមហើយចាប់ផ្តើមប៉ក់សាជាថ្មីឡើងវិញ ទៀត។

ការលេងមួយលើកមកនេះ ឃើញថាអ្នកទី១ជំពាក់អ្នកទី២ មួយគ្រាប់ហើយ បើលេង១លើកទៀតអ្នកទី១ជំពាក់គេ២ ឬ៣ គ្រាប់ទៀតសងគេវិញពុំរួចទេ លុះជំពាក់គេដល់១០គ្រាប់ ត្រូវ អោយគេដោះម្តងព្រោះល្បែងនេះ គេកំណត់ត្រឹមជំពាក់១០ ត្រូវ ដោះ ម្តងបានឈ្មោះថាចាញ់១ទឹកដែរ។ ប៉ុន្តែបើអ្នកទី១នេះ ប៉ក់ បានច្រើនគ្រាប់លើស ពីគ្រាប់ដែលកំណត់នោះ គេអាចសងទៅ អ្នកទី២វិញបាន។ សងប៉ុន្មានគ្រាប់ឈ្មោះថាបានរួចប៉ុណ្ណោះដែរ ។

ការដែលដោះនោះ គឺគេខោកក្បាលជង្គង់ដោយក្រញដៃ ដោះមាន២បែបគឺដោះបាយក្តៅ១បែប ដោះបាយត្រជាក់១បែប។ បើដោះបាយក្តៅគេខោកអោយខ្លាំងៗ ចំនួន១០ឬ១៥ដង។ បើ ដោះបាយត្រជាក់គេខោកតិចៗស្រាលៗចំនួន១១ ឬ១៥ដងដែរ។



www.elibraryofcambodia.org

ដោះហើយគេចាប់លេងសាជាថ្មីទៀត គេលេងតែរបៀបនេះ រហូតដល់ពេលឈប់។

ល្បែងនេះគេលេងដើម្បីជាការកំសាន្តផង ដើម្បីហាត់ហ្វឹក ហ្វឺនចិត្តគំនិត អោយស្គាល់អធ្យាស្រ័យរបស់មនុស្សទូទៅក្នុងការ លាក់កុំពុត ឬអាចកំបាំងអ្វីផ្សេងៗ ផង។


www.elibraryofcambodia.org

# ២២- ល្បែងចត្រង្គ[2]

## នាមនៃចត្រង្គ

**ល្បែងប្រភេទនេះ** កើតមានមកតាំងអំពីបុរាណកាល ជាល្បែងសម្រាប់កងទ័ពលេង អោយមានប្រាជ្ញាវាងវៃ ក្នុងការប្រើកលឧបាយក្នុងចម្បាំង។ ល្បែងនេះ មានឈ្មោះហៅ ៣យ៉ាងគឺ ល្បែងអុក ល្បែងឈើត្រង់ ល្បែងចត្រង្គ ។

**ល្បែងអុក**: បានជាហៅយ៉ាងនេះ ព្រោះល្បែងនេះ មានគោលដៅសម្លាប់ខុន។ តាមធម្មតា បើកូនចត្រង្គណាមួយ ដែលអ្នកលេង ចាប់យកទៅទង្គិចយ៉ាងខ្លាំង ដាក់ក្នុងក្រឡាដែលអាចស៊ីខុនបាន គេតែងបន្លឺពាក្យថា " អុក " ហេតុនោះល្បែងប្រភេទនេះទើបគេហៅថា " ល្បែងអុក " ។

**ឈើត្រង់**: ពាក្យនេះ ស្តាប់ទៅ ហាក់ដូចជាពាក្យផ្ទុយនឹង **ឈើវៀច** តែពិនិត្យរកន័យក្នុងពាក្យ **ឈើត្រង់** ដែលជាឈ្មោះ ល្បែងនេះមិនឃើញមានសោះ។ ព្រោះហេតុនោះ ពាក្យថា ឈើត្រង់ ក្នុងទីនេះប្រាកដជាក្លាយមកអំពីពាក្យថាចត្រង្គ។

**ចត្រង្គ**: ពាក្យនេះ ក្លាយមកអំពីភាសាសំស្ក្រឹត និងបាលីថា ចតុរង្គ ប្រែថា" មានអង្គបួន "។ ល្បែងនេះ មានវិធីលេងដូច

---

[2] -លោក យូ-អ៊ិន សមាជិកនៃក្រុមជំនុំព្រះត្រៃបិដក រៀបរៀង។



www.elibraryofcambodia.org

ជាចម្បាំងដែលមានសេនាកងទ័ពប្រកបដោយអង្គ៤ គឺ កងទ័ពដំរី កងទ័ពសេះកងទ័ពរថ និង កងទ័ពថ្មើរជើង ព្រោះហេតុនេះល្បែងនេះ ទើបឈ្មោះថាចតុរង្គ។ ពាក្យថា " ចត្រង្គ " នេះមិនមែនក្លាយមក អំពីពាក្យថា ចតុរ័ន្សដែលប្រែថា " មានជ្រុងបួន " ទេព្រោះមានន័យផ្ទុយពីល្បែងនេះ [3] ។

## កូនចត្រង្គ

ប្រដាប់សម្រាប់លេងល្បែងនេះ គេហៅថា កូនចត្រង្គ។ កូនចត្រង្គនោះ មានចំនួន៣២ សម្រាប់លេងដើរលើក្តារបួនជ្រុងដែលមានក្រឡា៦៤ ( ក្តារអុក ) ។ បណ្តាកូនទាំង៣២នោះ មានកូន២ហៅថាខុន ទុកជាស្តេចសោយរាជ្យ មានកូន២ហៅថានាងទុកជាព្រះអគ្គមហេសី មានកូន៤ ហៅថា គោលទុកជាសេនាបតី ឬ មេទព័ មានកូន៤ហៅថាសេះ មានកូន៤ហៅថាទូក មានកូន១៦ ហៅថាត្រី កូនទាំងអស់នេះ ទុកជាសេនារេហ៍ពល។

## កំណើតនៃកូនចត្រង្គ

(3) មានល្បែង២បែបទៀត ជាពួកចត្រង្គឬ ស្រដៀងគ្នានឹងចត្រង្គដែរ គឺ ស្កានិងវែក។

-ស្កា ពាក្យនេះហៅកាត់ខ្លីមកពី បាសកា ជាឈ្មោះល្បែងមួយប្រភេទពួកចត្រង្គដែរតែមានមេពីរ ហៅថាតៅ មានសណ្ឋានបួនជ្រុង មានរន្ធ៦ សម្រាប់លើកទំលាក់លើក្តារមានកូន២៤ឬ ៣០.........។

-វែក ឈ្មោះល្បែងមួយប្រភេទ ស្រដៀងនិងចត្រង្គ ខុសគ្នាតែឈ្មោះកូននិងការចាញ់ឈ្នះ មានបែបអោយស៊ីវែកទាំងសងខាង ឬបើអ្នកម្ខាងទាល់ច្រកត្រូវអ្នកលេងកៀរក្រសោប ស៊ីបានទាំងអស់ ជាល្បែងសម្រាប់ពួកទាហានលេង ដូចចត្រង្គដែរ។


www.elibraryofcambodia.org

កូនចត្រង្គទាំង៣២នោះ គេធ្វើដោយភ្លុកស្នែង ឬឈើផ្សេងៗ មានឈើនាងនួន និងដើមដៃខ្លាជាដើម តាមដែលគេមាន ធនធាននិងមានពេលអាចធ្វើបាន។ ដើម្បីកុំអោយអ្នកលេងច្រឡំកូនគ្នា កូនចត្រង្គ ទាំង៣២នោះ គេធ្វើអោយមានពណ៌ជា២ពួក ក្នុងមួយពួកៗ មាន១៦កូន គឺថាបើមួយពួកគេធ្វើដោយភ្លុក មួយពួកទៀតគេធ្វើដោយស្នែង បើមួយពួក គេធ្វើដោយឈើនាងនួន មួយពួកទៀត គេធ្វើដោយឈើគ្រញូងជាដើម។ ឯការធ្វើកូនចត្រង្គទាំងនោះ បើចង់អោយបានល្អស្អាត ហើយអោយមាន រូបរាងដូចៗ គ្នាគេត្រូវធ្វើដោយគ្រឿងក្រឡឹង វៀរលែងតែសេះ៤ ព្រោះសេះ គេក្រឡឹងពុំកើតទេ គេត្រូវឆ្លាក់ដោយគ្រឿងចម្លាក់។ ចំពោះអ្នកដែលគ្មាន គ្រឿងក្រឡឹងវិញ គេឆ្លាក់កូនទាំងអស់នោះដោយកាំបិតបន្ទោះ។

## រូបសណ្ឋាននៃកូនចត្រង្គ

បណ្តាកូនទាំង៣២នោះ ខុន២ គេធ្វើអោយមានរូបសណ្ឋាន ដូចសន្លឹកសីមា។ គោល៤គេធ្វើអោយមានរូបសណ្ឋានដូចសន្លឹកសីមាដែរតែមាឌតូចជាងខុន។នាង២ គេអោយមានកូនសណ្ឋានដូចតួចេតិយតែមាឌតូចជាងគោល។ សេះ៤ គេធ្វើអោយមានរូបសណ្ឋានថូឬសសីមា។ ត្រីទាំង១៦ គេធ្វើអោយមានរូបសណ្ឋានមូលសំប៉ែត ប៉ុនប្រាក់១កាក់ហើយមានធ្វើសញ្ញាអោយ


www.elibraryofcambodia.org

ដឹងថាពោះ ថាខ្នង ។ ឯក្តារចត្រង្គ មានរូបសណ្ឋាន៤ជ្រុងស្មើមិនកំណត់ទំហំទេហើយនៅខាងក្នុង ផ្ទៃក្តារនោះ មានក្រឡា៦៤។

ឯរូបសណ្ឋាន នៃកូនចត្រង្គ និងក្តារអុកទាំងនោះ ដូចមានរូបគំនូរខាងក្រោម៖



ខុន



គោល



នាង



ក្តារអុក



សេះ



ទូក



ត្រី



www.elibraryofcambodia.org

## របៀបរៀបកូនចត្រង្គ

មុននឹងនិយាយពីរបៀបរៀបកូនចត្រង្គ សូមនិយាយពីសមាសភាពនៃអ្នកលេងចត្រង្គសិន។ ឯអ្នកលេងចត្រង្គ ចែកជា២បក្ស ជាបក្សដែលត្រូវប្រកួតតស៊ូ ដោយតាំងចិត្តថាយកជ័យតែរៀងខ្លួន។ ក្នុងបក្សទាំង២ មិនមានកំណត់គ្នា ដោយចំនួនទេ គឺម្នាក់និងម្នាក់ តស៊ូគ្នាក៏បានបក្សម្ខាងតែម្នាក់ ឯបក្សម្ខាងទៀតមានគ្នា២ឬ៣នាក់ឡើងទៅក៏បាន។ អ្នកលេងទាំង២បក្សនេះត្រូវយកកូនចត្រង្គទាំង៣២ មកចែកជា ២ ពួកតាមពណ៌នៃក្នុងចត្រង្គហើយបើខ្លួនពេញចិត្តនឹងកូនចត្រង្គពណ៌ណា ក៏កាន់យកកូនចត្រង្គពណ៌នោះ មកជារបស់សំរាប់ខ្លួន។ ដែលចែកកូនចត្រង្គជា២ពួកនោះ ត្រូវអោយមានចំនួនកូន១៦ស្មើគ្នា គឺក្នុងមួយពួកៗត្រូវមានកូនដែលហៅថាខុន១ នាង១ គោល២ សេះ២ ទូក២ និង ត្រី៨។

មុននឹងលេង អ្នកលេងទាំងពីរបក្ស ត្រូវរៀបកូនចត្រង្គសម្រាប់ខ្លួនរៀងខ្លួនលើក្តារបួនជ្រុងមួយ (ក្តារអុក) ដែលមានក្រឡា៦៤ រៀបដាក់ក្នុងក្រឡាមួយៗ ដែលតាំងនៅត្រង់ទីបំផុត គឺក្រឡាដែលនៅផ្ទាល់នឹងក្រប។ ទាំង២បក្ស ត្រូវរៀបកូនចត្រង្គប្រទល់មុខគ្នា ដូច្នេះ៖

- ក្រឡាចុងក្តារទាំងពីរខាងដាក់ទូក២ ( ក្រឡាមួយដាក់ទូក


www.elibraryofcambodia.org

មួយ )។

- ក្រឡាបន្ទាប់ពីទូក ដាក់សេះ២ ( ក្រឡាមួយដាក់សេះមួយ )។

- ក្រឡាបន្ទាប់ពីសេះ ដាល់គោល២ ( ក្រឡាមួយដាក់គោលមួយ )។

- ពីរក្រឡាបន្ទាប់ពីគោល ដាក់ខុននិងនាងតែត្រូវដាក់កុំឲ្យស្របគ្នានិងបក្សម្ខាង។

ក្រឡាសង្កាត់ទី ៣ អំពីកូនដែលរៀបរួចមកហើយ ត្រូវរៀបត្រីទាំង៨ តែត្រូវរៀបដាក់ផ្កាប់សម្រាប់សំគាល់ថា មិនទាន់បក។

ចូរមើលរបៀបរៀបកូនចត្រង្គ ខាងក្រោមនេះ៖

បីខ្ទង់ខាងលើ កូនចត្រង្គនៃបក្សលើ

នេះខាងបក្សក្រោម

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ទូក | សេះ | គោល | នាល | ខុន | គោល | សេះ | ទូក | ១ |
| | | | | | | | | | ២ |
| | ត្រី | ត្រី | ត្រី | ត្រី | ត្រី | ត្រី | ត្រី | ត្រី | ៣ |
| | | | | | | | | | |
| | | | | | | | | | |
| ៣ | ត្រី | ត្រី | ត្រី | ត្រី | ត្រី | ត្រី | ត្រី | ត្រី | |
| ២ | | | | | | | | | |
| ១ | ទូក | សេះ | គោល | ខុន | នាល | គោល | សេះ | ទូក | |

នេះខាងបក្សលើ

បីខ្ទង់ខាងក្រោម កូនចត្រង្គនៃបក្សខាងក្រោម



www.elibraryofcambodia.org

## ដំណើរនៃកូនចត្រង្គ

កូនចត្រង្គទាំង៣២នោះ មានការដើរផ្សេងៗគ្នា តែមានដំណើរត្រូវគ្នាតាមឈ្មោះកូនគឺ៖

**១-ទូក** ដើរបណ្ដោយក្រឡាដោយឥតព្រមដែនដូចគំនូរ ខាងក្រោមនេះ៖




**២-សេះ** ដើរផ្លោះកាត់បញ្ឆៀង៣ ក្រឡាដូចគំរូខាងក្រោមនេះ៖




**៣-គោល** ដើរបាន៥ផ្លូវ គឺដើរទៅក្នុងក្រឡាមុខខ្លួនមួយក្រឡានិងក្រឡានៅជ្រុងទាំង៤ ដែលជាប់នឹងក្រឡាខ្លួន ដូចគំរូខាងក្រោមនេះ៖


www.elibraryofcambodia.org




**៤-នាង** ដើរបាន៤ផ្លូវ គឺដើរទៅក្នុងក្រឡានៅជ្រុងទាំង៤ ដែលជាប់នឹងក្រឡាខ្លួន ដូចគំរូខាងក្រោមនេះ៖




**៥-ខុន** ដែលមិនទាន់បក ដើររុលទៅក្នុងក្រឡាមុខខ្លួន មួយក្រឡាម្តងៗ ទាំងមានសិទ្ធត្រូវស៊ីកូនចត្រង្គជាបដិបក្សនឹងខ្លួន ដែលនៅក្នុងក្រឡាជ្រុង អមផ្លូវខ្លួនទាំងពីជ្រុងដូចមានគំរូខាងក្រោមនេះ៖





www.elibraryofcambodia.org

៦-ត្រី ដែលមិនទាន់បក ដើររុលទៅក្នុងក្រឡាមុខខ្លួនមួយក្រឡាម្តងៗ ទាំងមានសិទ្ធិត្រូវស៊ីកូនចត្រង្គជាបដិបក្សនឹងខ្លួនដែលនៅក្នុងក្រឡាជ្រុងអមផ្លូវខ្លួនទាំងពីរជ្រុង ដូចមានគំរូខាងក្រោមនេះ ៖




បើត្រីនេះបកហើយ ត្រូវដើរបាន៤ផ្លូវ ដូចនាង។ ត្រីដែលឡើងទីជាត្រីបក ( ដើរបកមកក្រោយបាន ) នោះ ចំពោះតែត្រីណាដែលដើរដល់ក្រឡាជាព្រំដែន នៃកូនចត្រង្គជាបដិបក្ស គឺ ក្រឡាទាំង៨ដែលជាត្រីបកនោះ គេត្រូវដាក់ផ្លាកពោះ ដើម្បីកុំឲ្យច្រឡំនឹងត្រីមិនទាន់បក ។

ដំណើរនៃកូនចត្រង្គដូចបានពោលមកហើយនេះគេសន្មត់ហៅថា " ដើង " គឺដើងទូក ដើងសេះ ដើងគោល ដើងនាង ដើងខុន ដើងត្រី។

## ឥទ្ធិពលនៃកូនចត្រង្គ

កូនចត្រង្គទាំង៣២ មានឥទ្ធិពលខ្លាំងនិងខ្សោយខុសគ្នា តែស្មើគ្នាដោយឈ្មោះកូនគឺ ទូក២ និង សេះ២ មានកម្លាំងខ្លាំងក្រៃ


www.elibraryofcambodia.org

លែងជាងកូនចត្រង្គទាំងអស់។ តែទូកគេអាចបន្ថយឥទ្ធិពលមក ត្រឹមត្រីបកបានហៅថា " ទូកបក " សម្រាប់អ្នកលេងជើងឯកលេង ប៉ះនឹងអ្នក លេងជើងអន់។ ទូកបកនេះគេត្រូវរៀបដាក់ផ្ទារ ក្នុង ពួកក្រឡាសង្កាត់ទី២ត្រង់ ក្រឡាណាក៏បាន។ គោល៤មានកម្លាំង ខ្លាំងដែរតែមិនដល់ កម្លាំងទូកនិងសេះទេ។ នាងនិងត្រីបក មាន កម្លាំងអន់ជាងគោលទាំង៤ ។ ត្រីមិនទាន់បកមានកម្លាំងអន់ជាង នាង និងត្រីបក។ ឯខុននឹងថាមានឥទ្ធិពលឬគ្មានឥទ្ធិពលពុំបាន ទេ ព្រោះខុនមានមុខនាទីតែរត់គេច កុំអោយគេ សម្លាប់ខ្លួន ហើយដែលស៊ីគេបាន ចំពោះតែគ្មានគេស៊ីខ្លួនវិញ។

**ផ្តើមចេញគយុទ្ធ**

កាលអ្នកលេងបានរៀបកូនចត្រង្គរួចស្រេចហើយតទៅត្រូវ ចេញដំណើរកូនចត្រង្គ។ បណ្តាអ្នកលេងទាំង២បក្ស ត្រូវអោយ បក្សណាមួយចេញដំណើរកូនចត្រង្គមុន ស្រេចហើយត្រឹមនិយា-យគ្នា។ តែកាលបើលេងលើកទី១ មានចាញ់មានឈ្នះហើយដល់ មកលេងលើកទី២ ត្រូវបក្សឈ្នះចេញដំណើរកូនចត្រង្គមុន។តាម ទម្លាប់នៃអ្នកលេងចត្រង្គ មុនដំបូងបង្អស់ច្រើនដើរត្រីនៅមុខខុន អោយបានត្រី ២ ឬ ៣ សិនរួចហើយ ទើបចេញដំណើរកូន ចត្រង្គដទៃ តាមដំណើរនៃកូន ដូចបានពោលហើយលើកលែង


www.elibraryofcambodia.org

តែដំណើរនាង និងខុនចេញ។ ព្រោះនាង និងខុន ធ្វើដំណើរមុនដំបូងមានសិទ្ធិដើរផ្លោះក្រឡាបាន គឺនាងដើរផ្លោះរំលង១ក្រឡាដែលនៅមុខខ្លួនទៅនៅក្នុងក្រឡាទី៣ ត្រង់កន្លែងដែល រៀបត្រីជាដំបូង។ ឯខុនដើរផ្លោះកាត់ ចំហៀង៣ក្រឡាដែលនៅឆ្វេងខាងមុខខ្លួន។ តែតពីនោះមកនាង និងខុននេះ ត្រូវដើរតាមរបៀបប្រក្រតីខ្លួនវិញ។ ចូលមើលរបៀបចេញដំណើរ មុនដំបូងដូចគំរូខាងក្រោមនេះ៖

បីខ្ទង់ខាងលើ កូនចត្រង្គនៃបក្សលើ




បីខ្ទង់ខាងក្រោម កូនចត្រង្គនៃបក្សក្រោម


www.elibraryofcambodia.org

## ពាក្យសម្រាប់ប្រើក្នុងល្បែងចត្រង្គ

ក្នុងល្បែងចត្រង្គ មានពាក្យថា ស៊ី ចង ផាយ អង់ អុក បិទ អុកបែក អាប់ ជាពាក្យនិយាយប្រាប់គ្នាអោយដឹងតាមហេតុការណ៍ដែលមាន។

**ស៊ី**: ពាក្យនេះ ប្រើនិយាយចំពោះកូនចត្រង្គណា នៅក្នុងក្រឡាដែលជាជើងរបស់គេ គេអោយស៊ីកូនចត្រង្គនោះបានដូចទូកនៅក្នុងជើងសេះ សេះអាចស៊ីទូកនោះ មើលគំរូខាងក្រោមនេះ៖

| | | |
|---|---|---|
| | | ទូក |
| សេះ | | |
| | | |

ទូកនៅក្នុងជើងសេះ។
ទូកនិងសេះជាបក្សផ្សេងគ្នា។

**ចង**: កូនចត្រង្គណានៅក្នុងក្រឡាដែលជាជើងនៃកូនចត្រង្គគេដែលគេអាចស៊ីបាន នោះគេត្រូវរកកូនចត្រង្គដទៃ ដែលមានជើងអាចស៊ីទៅគេវិញ អោយដើរមកក្នុងក្រឡាផ្សេង គឺបើគេស៊ីមកយើងមានកូនស៊ីទៅគេវិញហៅថា " ចង " ដូចមានគំរូខាងក្រោមនេះ៖

www.elibraryofcambodia.org

| | | | |
|---|---|---|---|
| | | ទូក | |
| សេះ | | | នាង |
| | | | |

ទូកនៅក្នុងជើងសេះ។
ទូកនិងនាងជាបក្សមួយ។

**ផាយ**: ពាក្យនេះ ប្រើនិយាយចំពោះខុននៅក្នុងជើងទូក ដែលមានកូន ចត្រង្គណាមួយ ជាបក្សខាងទូកនៅស្ទះរាំង កាល បើគេដើរកូនដែលស្ទះរាំងជើងទូកនោះ គេពោលថា " ផាយ " ព្រោះទូកនោះអាចស៊ីខុនបាន ខុននោះត្រូវរត់ បើរត់មិនរួច ឈ្មោះ ថាចាញ់គេ ដូចមានគំរូខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | | |
| ទូក | | ត្រី | ខុន |
| | | | |

ត្រី និងខុនជាបក្សមួយ។
ត្រីស្ទះរាំងជើងទូក។

**អង់** ពាក្យនេះ ប្រើនិយាយចំពោះទូក ដែលដើរទៅនៅក្នុង ក្រឡាដែលមានសិទ្ធិស៊ីខុន តែស៊ីមិនទាន់បាន ព្រោះខុននោះ មានទ័ពខ្លួននៅស្ទះរាំងផ្លូវទូកហៅថា " អង់ " ដូចមានគំរូខាង ក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | | |
| ទូក | | ត្រី | ខុន |
| | | | |

ត្រី និងខុនជាបក្សមួយ។
ត្រីស្ទះរាំងជើងទូក។

www.elibraryofcambodia.org

**អុក:** ពាក្យនេះប្រើនិយាយចំពោះកូនចត្រង្គណា ដែលដើរទៅក្នុងក្រឡាមានជើងខ្លួនត្រូវស៊ីខុន ដោយគេទង្គិចកូននោះយ៉ាងខ្លាំងហើយពោលថា " អុក " ។ តែខុននិងខុនមិនអាចអុកគ្នាបានទេ ព្រោះខុនទាំង២ ត្រូវដើរចៀសកុំអោយប៉ះជើងគ្នាទៅវិញទៅមកជាដរាប ដូចមានគំរូខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | | |
| ទូក | | | ខុន |
| | | | |

ទូកនិងខុនជាបក្សផ្សេងគ្នា។
ទូកមានជើងត្រូវស៊ីខុន។

**បិទ:** ពាក្យនេះ ប្រើនិយាយចំពោះកូនចត្រង្គណា ដាក់បិទផ្លូវជើងទូក ដែលគេអុកខុសហើយដើម្បីការពារកុំអោយគេស៊ីខុននោះដូចមានគំរូខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | | |
| ទូក | | + | ខុន |
| | នាង | | |

នាង និងខុនជាបក្សមួយ។
នាងត្រូវដើរមកបិទជើងទូក។

**អុកបែក** ៖ កូនចត្រង្គណាមួយដែលអុកខុនហើយ ហើយអាចស៊ីកូនដទៃបានផង ហៅថា "អុកបែក" ឧទាហរណ៍ ដូចគេ


www.elibraryofcambodia.org

យកសេះអុកខុន, សេះនោះអាចស៊ីទូកបាន នៅវេលាដែលបក្សម្ខាងដើរខុនចេញហើយ ដូចមានគំរូខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | ខុន | |
| សេះ | | | |
| | | ទូក | |

ខុននិងទូកជាបក្សមួយ
ដែលនៅក្នុងជើងសេះគេ ។

**អាប់** ៖ ពាក្យនេះសម្រាប់ប្រើហៅខុន ដែលទ័ពគេតាមដេញ, កាលខុននោះត្រូវដើរ តែដើរមិនរួច ព្រោះក្រឡានៅជុំវិញខ្លួន សុទ្ធតែជាជើងរបស់គេ, ខុននោះត្រូវផ្ដួលខ្លួនដេកក្នុងក្រឡាខ្លួន ហើយគេពោលថា "អាប់"។ ខុនដែលអាប់នេះ មិនបានឈ្មោះថាចាញ់គេ ទាំងខាងគេ ក៏មិនឈ្មោះថាឈ្នះដែរ ដូចមានគំរូខាងក្រោមនេះ ៖




ទូកនិងគោលជាបក្សមួយ
ដែលមានជើងព័ទ្ធខុនជាប់ ។


www.elibraryofcambodia.org

## តស៊ូផ្សងព្រេង

កាលបើទ័ព គឺកូនចត្រង្គរបស់បក្សណាមួយ ដែលបក្សម្ខាងបានស៊ីអស់ហើយ នៅសល់តែខុនមួយ ខុននោះត្រូវខុនដែលមានទ័ពគឺ កូនចត្រង្គនៅសល់ច្រើន តាមដេញសម្លាប់ ទាល់តែរត់លែងរួច ។ តែដែលថាមកនេះ បានចំពោះតែខុននោះ មានត្រីមិនទាន់បក បើត្រីនោះបកហើយ ខុនទាំង ២ ត្រូវដើរផ្សងព្រេង ដោយវិធីរាប់ជើង បើរាប់ទៅ ឃើញហួសព្រំដែន ដែលបានកំរិតទុកហើយគេទុកជាស្មើគ្នា, ខុនទាំង ២ មិនឈ្នះមិនចាញ់ ។ តែបើខុនឯកឯងនោះ ស្លាប់មុននឹងដល់ព្រំដែននៃការរាប់ ដែលបានកំរិតទុក គេទុកជាចាញ់ ។

ឯវិធីរាប់ជើងនោះ មុននឹងរាប់ គេត្រូវបូករួមកូនចត្រង្គទាំង ២ បក្សបញ្ចូលគ្នាសិន គឺ បើកូនទាំងអស់មាន ៤ ត្រូវចាប់រាប់ពី ៥ ឡើងទៅ, បើកូនទាំងអស់ មាន ៥ ត្រូវចាប់រាប់ពី ៦ ឡើងទៅ ។ល។ តាមទម្លាប់ ត្រូវអ្នកលេងចត្រង្គ ដែលជាបក្សអន់ មានសល់តែខុនមួយ ដើរខុនហើយរាប់ឲ្យឮ ដល់ត្រចៀកនៃអ្នកដទៃ ផង ។

## ព្រំដែននៃការដើររាប់ជើង

ការដើរហើយរាប់ជើងផងនោះ ពោលតាមទម្លាប់នៃអ្នកលេងចត្រង្គថា ៖ ត្រូវរាប់ទៅតាមជើងនៃកូនចត្រង្គមួយ ៗ ដែលសល់នៅ ដូចមាន កំណត់ទុកតទៅនេះ ៖


www.elibraryofcambodia.org

បើខុនដែលមានសល់កូនចត្រង្គ គឺ

ទូក ១ រាប់ ១៦ ហៅថា ជើងទូក,

សេះ ១ រាប់ ៦៤ ហៅថា ជើងសេះ,

គោល ១ រាប់ ៤៤ ហៅថា ជើងគោល,

ត្រីបក ឬ នាង រាប់៦៤ ហៅថា ជើងត្រី ។

បើទូក, សេះ, គោល, នៅសល់ទាំងមួយគូ ៗ ត្រូវរាប់កាត់ពាក់កណ្តាលចោល គឺ

ទូក ២ រាប់ ៨ វិញ

សេះ ២ រាប់ ៣២ វិញ

គោល ២ រាប់ ២២ វិញ ។

ឯត្រីបក បើមានច្រើន ក៏មិនបន្ថយចំនួនរាប់ឡើយ ។

បើនៅសល់កូនចត្រង្គលាយចម្រុះគ្នា ត្រូវរាប់តាមកូនចត្រង្គណា ដែលមានជើងតិចជាងកូនឯទៀត គឺ៖

បើសល់ទូក ១ និងសេះ ២ ឬ ១ រាប់ ១៦ (យកជើងទូក),

បើសល់ទូក ១ និងគោល ២ ឬ ១ រាប់ ១៦ (យកជើងទូក)

បើសល់ទូក ១ និង នាង ឬត្រីបក រាប់ ១៦ (យកជើងទូក)

បើសល់សេះ ២ ឬ ១ និងគោល ២ រាប់ ២២ (យកជើងគោល)

បើសល់សេះ ១ និងគោល ១ រាប់ ៤៤ (យកជើងគោល)



www.elibraryofcambodia.org

បើសល់សេះ ២ និងគោល ១ រាប់ ៣២ (យកជើងសេះ)

បើសល់សេះ ១ និងនាងឬត្រីបក រាប់ ៣០ (យកជើងណាក់បាន)

**បើសល់សេះ ២ និងនាងឬត្រីបក រាប់ ៣២ (យកជើងសេះ)។**

**នៅមានការដើរផ្សងព្រេង ដោយវិធីរាប់មួយបែបទៀត ដូចនឹងពោលតទៅនេះ៖**

**បណ្ដាបក្សទាំងពីរ បក្សមួយ នៅមានសល់តែខុននិងកូនចត្រង្គណាមួយ តែមួយ** បក្សមួយទៀត មានសល់កូនចត្រង្គច្រើនជាង តាំងអំពីពីរបីឡើងទៅ ។ កាលបើមានសល់កូនបែបនេះ គេត្រូវរាប់ ៦៤ ហើយចាប់រាប់ពី១ រៀងរហូតដល់ ៦៤ ។ បក្សអន់ (ដែលមានតែខុន ១ និង កូន ១) ត្រូវរាប់ រាប់ឲ្យឮ ៗ ។ បើបក្សដែលមានព្រៀបជាងនោះមានត្រី ហើយត្រីនោះដើរដល់ក្រឡាបក បក្សអន់ ត្រូវត្រឡប់រាប់តាមអំណាចជើងនៃកូនចត្រង្គ ដូចដែលពោលខាងលើនោះវិញ ។

## ការប្រុងប្រយ័ត្នក្នុងពេលកំពុងតយុទ្ធ

អ្នកលេងចត្រង្គ កាលបើចាប់ផ្ដើមលេង ត្រូវមានការប្រុងប្រយ័ត្ន ២យ៉ាង គឺ ប្រយ័ត្នកុំឲ្យកូនចត្រង្គណាខាងគេដែលមានឥទ្ធិពលតិច ស៊ីកូនចត្រង្គខ្លួន ដែលមានឥទ្ធិពលច្រើន ដូចត្រីខាងគេ ត្រូវស៊ីសេះ ទូក គោល ជារបស់ខ្លួនទាំងត្រូវប្រយ័ត្នកុំឲ្យគេស៊ី


www.elibraryofcambodia.org

ដោយឥតថ្នូរ ។ មួយទៀត ត្រូវប្រយ័ត្នជាបំផុត កុំឲ្យកូនចត្រង្គខាងគេ ចោមសម្លាប់ខុនជារបស់ខ្លួន ។ ព្រោះគោលដៅក្នុងល្បែងចត្រង្គ ចំពោះត្រង់សម្លាប់ខុន, បើគេសម្លាប់ខុនបានហើយ ចាត់ទុកជាចាញ់គេ អស់ផ្លូវតវ៉ា ។

## ទោសក្នុងការលេងចត្រង្គ

ល្បែងចត្រង្គ ធ្វើឲ្យអ្នកលេងខ្លះដក់ជាប់ចិត្ត រហូតដល់ភ្លេចបាយ ភ្លេចទឹក ភ្លេចប្រកបការងារដែលត្រូវធ្វើ ទាំងរយៈវេលាដែលលេងមកកន្លងទៅច្រើនម៉ោងហើយ ក៏អ្នកលេងខ្លះភ្លេចគិតដល់ លុះដល់ឈប់លេងព្រោះហេតុតែប្រើឥរិយាបថ អង្គុយគិតដើងចត្រង្គយូរ ហួសពេលវេលា ព្រមទាំងខានបរិភោគបាយទឹក អ្នកលេងចត្រង្គខ្លះ ច្រើនទៅជាខ្យល់ចាប់ ដេកមិនលក់ ងេងងោងស្មារតី រសាប់រសល់ កាន់ការអ្វីមិនមុតមាំ ។

ហេតុអ្វីក៏ល្បែងនេះ ធ្វើឲ្យអ្នកលេងជក់ចិត្តខ្លាំងម្លេះ ? ព្រោះល្បែងនេះ អ្នកលេងត្រូវប្រើគំនិតគិតឲ្យឃើញច្រើនជាន់ច្រើនផ្លូវ ត្រូវប្រើស្មារតីប្រុងប្រយ័ត្ន គ្មានបន្ធូរដាដរាប ត្រូវប្រើកលឧបាយគ្មានស្រាក ក្នុងទីបំផុត ក៏ត្រូវចាញ់ ឬឈ្នះ ឬក៏ស្មើគ្នា ។ បណ្ដាបក្សទាំងពីរ បក្សដែលចាញ់ គិតថា " បានជាចាញ់ ព្រោះអញគិតខុសត្រង់នេះ ព្រោះភ្លេចស្មារតីត្រង់នោះ ព្រោះចាញ់កលគេត្រង់នេះ ដូច្នេះដល់ក្ដារទី២ អញត្រូវប្រុងប្រយ័ត្នកុំឲ្យភ្លាត់សោះ


www.elibraryofcambodia.org

ត្រូវយកជ័យឲ្យបានវិញ " ។ ចំណែកខាងបក្សឈ្នះ សប្បាយចិត្ត ខ្លាំង តាំងចិត្តថា "ដល់ក្ដារទី ២ អញ ត្រូវប្រឹងយកជ័យឲ្យបាន ទៀត" ។ តែគួរឲ្យអនិច្ចា ! ការតាំងចិត្តថានឹងយកជ័យឲ្យបាននៃ បក្សទាំង ២ នោះ ឥតបានដូចបំណងរាល់លើក រាល់ក្ដារនោះ ឡើយ ម្ល៉ោះហើយ អ្នកលេងទាំងពីរបក្ស ក៏ចេះតែមិនអស់ចិត្ត រៀងខ្លួន បើទុកជាលេងទៅចាញ់គេ ក៏ចិត្តមិនព្រមចាញ់ បើទុក ជាលេងទៅឈ្នះគេ ក៏មិនសុខចិត្តនឹងការឈ្នះមិនដំណំ ឬឈ្នះ មិនច្រើន ។ ព្រោះអាស្រ័យហេតុនេះ ទើបអ្នកលេងល្បែងនេះដក់ ចិត្តជាខ្លាំង ។

អ្នកលេងចត្រង្គ មាន ២ ពួក គឺពួកមួយ ចូលចិត្តលេងមិន ភ្នាល់ មួយពួកទៀត ចូលចិត្តលេងមានដាក់តំណាំង ។ អ្នកលេង ទាំង ២ ពួកនេះ បាននាមថាជាអ្នកប្រព្រឹត្តអបាយមុខ ត្រូវទទួល សេចក្ដីវិនាស នៃសុខភាពក្នុងរាងកាយ ខូចពេលវេលាដែលត្រូវ ប្រកបការងារ បើលេងហើយមានភ្នាល់ផង ក៏ត្រូវជួបសេចក្ដី វិនាស នៃធនធានទ្រព្យសម្បត្តិច្រើនលើសលុប ។

## គុណក្នុងការលេងចត្រង្គ

ប្រយោជន៍ក្នុងការលេងចត្រង្គ មានតិចតួចស្ដួចស្ដើង ណាស់ ស្ទើរតែថាមានពុំបាន ។ តែបើរាវរកឲ្យជ្រៅឆ្ងាយទៅ ក៏ គង់ឃើញមានខ្លះថា ៖ ល្បែងចត្រង្គនេះ គួរចាត់ទុកជាកីឡា ផ្នែក


www.elibraryofcambodia.org

ខាងមនោពលកម្ម គឺ ល្បែងបង្ហាត់ចិត្តឲ្យរឹង ធ្វើចិត្តឲ្យមានមានះ ប្រកាន់មាំ ទ្រាំតស៊ូក្នុងកិច្ចការដែលជាមុខនាទីខ្លួនត្រូវធ្វើ ។ គុណប្រយោជន៍ដោយត្រង់ក្នុងល្បែងនេះ ចំពោះវីរបុរស យកតម្រាប់តាមកលឧបាយក្នុងល្បែងចត្រង្គ ទៅប្រើក្នុងនយោបាយដឹកនាំប្រទេសជាតិ ឬយកទៅប្រើក្នុងសឹកសង្គ្រាម ។ ព្រោះអ្នកធ្វើនយោបាយក្តី អ្នកធ្វើចម្បាំងក្តីត្រូវជាអ្នកចេះធ្វើកលឧបាយច្រើនជាន់ ច្រើនផ្លូវ មានប្រាជ្ញាវាងវៃ មានកលល្បិចច្រើនស្រទាប់ ធ្វើឲ្យគូសត្រូវងងឹតមុខ វង្វេងស្មារតី ឲ្យភ្លាត់ស្នៀត ទើបយកជ័យបាន ប្រៀបដូចជាអ្នកលេងចត្រង្គ ដែលមានប្រាជ្ញាវាងវៃ អាចចេះប្រើកលឧបាយយកជ័យពីគូប្រកួតនឹងខ្លួនបាន ដូច្នោះឯង ។

## បរិយោសនកថា

អត្ថបទស្តីពីល្បែងចត្រង្គនេះ ខ្ញុំបាននិយាយសព្វគ្រប់អស់ហើយគួរចាត់ទុកថាជា **តម្រាល្បែងចត្រង្គ** បានពិត ដែលនៅសល់ចន្លោះតែ ត្រង់និយាយប្រាប់ផ្លូវ ប្រាប់ឧបាយ ឲ្យអ្នកអានលេងចត្រង្គទៅហើយពូកែវាងវៃ ប៉ិនប្រសប់ ចេះប្រើកលឧបាយឲ្យឈ្នះគេរាបរហូត ឲ្យទៅជាអ្នកចត្រង្គជើងឯក ។ បានជានៅសល់ត្រង់រឿងនេះ ព្រោះខ្ញុំរកពាក្យសរសេរប្រាប់ពុំកើត ពុំដឹងជានិយាយដូចម្តេច ។ ព្រោះការវាងវៃប៉ិនប្រសប់ការយល់ដើងចត្រង្គច្រើនជាន់ច្រើនស្រទាប់នៃជនណា ពិតជាជននោះ ឧស្សាហ៍លេង


www.elibraryofcambodia.org

ចត្រង្គ ជួនលេងប៉ះនឹងអ្នកនេះ ជួនលេងប៉ះនឹងអ្នកនោះ ការប៉ិនប្រសប់ក្នុងជើងចត្រង្គនោះ ក៏កើតមានបន្តិច ៗ ជាលំដាប់ទៅ ។ តែចំពោះមនុស្សខ្លះ បើទុកជាព្យាយាមលេងយ៉ាងណា ក៏មិនបានទៅជាអ្នកចត្រង្គជើងឯកដែរ ការណ៍នេះព្រោះអ្វី ? ព្រោះអ្នកនោះឯង មានសតិប្បញ្ញាដែលជិតជាប់ពីកំណើត ( សជាតិកប្បញ្ញា ) ទន់អន់ជាខ្លាំង ។

អ្នកប្រព្រឹត្តគិតតែល្បែងរែងវិនាស
អ្នកលះលាសចៀសចាកល្បែងរែងចម្រើន
អ្នកព្យាយាមប្រកបការណាឲ្យកើន
រែងចំរើនដោយក្ដីសុខទុក្ខគ្មានហោង ។


www.elibraryofcambodia.org